ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្ដីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥

នៅក្នុងឆ្នាំ២០២៤នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារលើគ្រប់វិស័យ ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥

### ១-មុខងារនីតិកម្ម

- បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ **ចំនួន១២លើក** ដើម្បី៖

១- ពិនិត្យ និងសម្រេចលើសេចក្ដីព្រាងច្បាប់ ចំនួន៦ច្បាប់។

២- ពិនិត្យ និងសម្រេចអំពីតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់គណៈកម្មការទាំង១០ព្រឹទ្ធសភា។

៣-ពិនិត្យ និងសម្រេចអំពីការចាត់តាំងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគ។

៤- ពិនិត្យ និងសម្រេចអំពីការចាត់តាំងក្រុមសមាជិកាព្រឹទ្ធសភា។

៥- ពិនិត្យ និងសម្រេចអំពីការចាត់តាំងក្រុមជនបង្គោលប្រឆាំងអំពើពុករលួយរបស់ព្រឹទ្ធសភា។

៦- ពិនិត្យ និងសម្រេចអំពីការចាត់តាំងគណៈកម្មការក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា។

៧- ពិនិត្យ និងសម្រេចអំពីការបង្កើតក្រុមមិត្តភាពព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ជាមួយព្រឹទ្ធសភា រដ្ឋសភានៃបណ្ដាប្រទេសជាមិត្ត។

៨- ពិនិត្យ និងសម្រេចអំពីការចាត់តាំងក្រុមសមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដែលទទួលបន្ទុកសហប្រតិបត្តិការជាមួយអង្គការអន្តរសភា។

៩- ពិនិត្យ និងសម្រេចអំពីការចាត់តាំងក្រុមសមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា សម្រាប់ត្រៀមសហការ និងចូលរួមជាមួយរដ្ឋសភាក្នុងកិច្ចប្រជុំអង្គការអន្តរសភា។

១០- ពិនិត្យ និងសម្រេចអំពីតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ក្រុមសមាជិកាព្រឹទ្ធសភា។

១១- ប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី។

១២- បោះឆ្នោតជ្រើសរើសអនុប្រធានទី១ និងអនុប្រធានទី២ព្រឹទ្ធសភា នីតិកាលទី៥។

១៣-បោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការទី២ និងគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន ព្រឹទ្ធសភា នីតិកាលទី៥ និង

១៤-ពិនិត្យ និងសម្រេចលើរបាយការណ៍ស្តីពី លទ្ធផល និងសកម្មភាពការងាររបស់ព្រឹទ្ធសភា នីតិកាលទី៥ នៅចន្លោះសម័យប្រជុំលើកទី១ និងលើកទី២។

- បានរៀបចំបើកសម័យប្រជុំពេញអង្គព្រឹទ្ធសភា និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ **ចំនួន ៧លើក** ដែលមានរបៀបវារៈដូចខាងក្រោម៖

១-ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពី ឯកភាវូបនីយកម្មនៃវិធានមួយចំនួនពាក់ព័ន្ធនឹងការដឹកជញ្ជូនអន្តរជាតិតាមផ្លូវអាកាស។

២-ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តលុបចោលកិច្ចព្រមព្រៀងស្តីពី ការជំរុញ និងសម្រួលពាណិជ្ជកម្មតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម។

៣-ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃកិច្ចព្រមព្រៀងស្តីពី ការទទួលយកបទប្បញ្ញត្តិបច្ចេកទេសរួម នៃអង្គការសហប្រជាជាតិសម្រាប់យានយន្ត បរិក្ខារ និងគ្រឿងបន្លាស់ដែលអាចបំពាក់ និងប្រើប្រាស់ទៅលើយានយន្ត និងលក្ខខណ្ឌសម្រាប់ការទទួលស្គាល់ទៅវិញទៅមកនៃការផ្តល់អនុលោមភាពដោយឈរលើមូលដ្ឋាននៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិ។

៤-ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ប្រព័ន្ធទឹកកខ្វក់។

៥-ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។

៦-ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ ២០២៥។

៧-ប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី។

៨-បោះឆ្នោតជ្រើសរើសអនុប្រធានទី១ និងអនុប្រធានទី២ព្រឹទ្ធសភា នីតិកាលទី៥។

៩-បោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការទី២ និងគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន ព្រឹទ្ធសភា នីតិកាលទី៥។

១០-បោះឆ្នោតជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ១រូប ជំនួសសមាជិកឧត្តមក្រុមប្រឹក្សាអង្គចៅក្រម ដែលត្រូវបញ្ចប់អាណត្តិ។

១០-ស្តាប់របាយការណ៍ស្តីពី លទ្ធផល និងសកម្មភាពការងាររបស់ព្រឹទ្ធសភា នីតិកាលទី៥ នៅចន្លោះសម័យប្រជុំលើកទី១ និងលើកទី២។

- សកម្មភាពការងាររួមរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បាន៖

  - អញ្ជើញចូលរួមក្នុងពិធីបើកសម័យប្រជុំដំបូងព្រឹទ្ធសភា សម្រាប់នីតិកាលទី៥ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅវិមានព្រឹទ្ធសភា។

- អញ្ជើញប្រកាសសុពលភាពអាណត្តិរបស់សមាជិកនីមួយៗ និងបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានទាំងពីរនៃព្រឹទ្ធសភា នីតិកាលទី៥ និងអញ្ជើញថ្លែងសុន្ទរកថាទៅកាន់អង្គព្រឹទ្ធសភា ក្នុងឱកាសទទួលតំណែងជាប្រធានព្រឹទ្ធសភា នីតិកាលទី៥ នៅវិមានព្រឹទ្ធសភា និង
- អញ្ជើញចូលរួមព្រះរាជពិធីសច្ចាប្រណិធាន ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះបរមរាជវាំង។

- បានរៀបចំចាត់ចែងជូនគណៈកម្មការនានារបស់ព្រឹទ្ធសភា អញ្ជើញដឹកនាំកិច្ចប្រជុំនានា រួមមាន៖
  - ប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យឆ្លងសេចក្តីព្រាង សេចក្តីសម្រេចស្តីពី តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់គណៈកម្មការទាំង១០ព្រឹទ្ធសភា។
  - ប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការ ជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ចំនួន៦ច្បាប់ និង
  - ប្រជុំពិភាក្សាលើសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

## ២-មុខងារតាមដានការអនុវត្តច្បាប់

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនគណៈកម្មការនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា រួមមាន៖

❖ គណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាស្វែងយល់អំពីដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ សិទ្ធិរបស់ជនជាតិដើមភាគតិចដែលទទួលបាននូវកម្មសិទ្ធិជីសមូហភាព សិទ្ធិរបស់អ្នកជាប់ឃុំ ការអនុវត្តក្រមទាំង៤ និងការផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងការអភិវឌ្ឍតំបន់ត្រីកោណ កម្ពុជា-ឡាវ-វៀតណាម CLV-DTA នៅខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី និងបានជួបពិភាក្សាការងារជាមួយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដឹកនាំដោយ **ឯកឧត្តម កែវ សុទ្ធិ** អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងតំណាងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (OHCHR) ដើម្បីស្វែងយល់អំពីការអនុវត្តការងារលើវិស័យសិទ្ធិមនុស្សប្រចាំកម្ពុជា និងការការពាររបាយការណ៍ទាំង៥ រួមមាន៖ របាយការណ៍ស្តីពី ការត្រួតពិនិត្យឡើងវិញជាសកលតាមកាលកំណត់(UPR) របាយការណ៍ស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ របាយការណ៍ស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ របាយការណ៍ស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ និងរបាយការណ៍ស្តីពី ការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ។

❖ គណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីជួបពិភាក្សាការងារជាមួយរដ្ឋបាលខេត្ត និងអង្គភាពពាក់ព័ន្ធថ្នាក់ក្រោមជាតិ ដើម្បីស្វែងយល់ពីបញ្ហាប្រឈមពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តកំពង់ចាម និងខេត្តមណ្ឌលគិរី។

- ❖ គណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីជួបពិភាក្សាការងារ ជាមួយរដ្ឋបាលខេត្ត ដើម្បីស្វែងយល់ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តកំពង់ស្ពឺ។
- ❖ គណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាស្វែងយល់អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ ច្បាប់ស្តីពីរបបសារព័ត៌មាន ច្បាប់ស្តីពីការងារ ការផ្សព្វផ្សាយព័ត៌មាន ការអភិវឌ្ឍលើវិស័យនានា និងពិនិត្យសកម្មភាពចេញ-ចូលរបស់ភ្ញៀវជាតិ-អន្តរជាតិ នៅច្រកទ្វារព្រំដែនអន្តរជាតិ ភ្នំដី (គីឡូ១៣) ស្រុកសំពៅលូន និងនៅច្រកទ្វារព្រំដែនអន្តរជាតិ ដូងស្រុកកំរៀង ខេត្តបាត់ដំបង។
- ❖ គណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចុះជួបពិភាក្សាការងារ ជាមួយអង្គបោះឆ្នោតនៅតាមមូលដ្ឋានអំពី " **ការចុះបញ្ជីអត្រានុកូលដ្ឋាន** " ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម សមាជិក សមាជិកាក្រុមប្រឹក្សាឃុំ-សង្កាត់ ស្មៀនឃុំ-សង្កាត់ នាយប៉ុស្តិ៍នគរបាលរដ្ឋបាល ឃុំ-សង្កាត់ និងមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធ សរុបចំនួន៧៦នាក់ នៅសាលប្រជុំក្រុងតាខ្មៅ ខេត្តកណ្តាល។
- ❖ គណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាស្វែងយល់ និងប្រមូលព័ត៌មានអំពីការផ្សព្វផ្សាយច្បាប់ និងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យជំនាញជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តព្រៃវែង និងបានអញ្ជើញជួបពិភាក្សាការងារជាមួយ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងសហការី ដើម្បីស្វែងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម និងចក្ខុវិស័យទៅមុខរបស់ក្រសួង នៅសាលប្រជុំព្រះវិហារទីស្តីការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។
- ❖ គណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាស្វែងយល់ និងប្រមូលព័ត៌មានអំពីការផ្សព្វផ្សាយច្បាប់ និងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យជំនាញជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តស្វាយរៀង។
- ❖ គណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាស្វែងយល់ និងប្រមូលព័ត៌មានអំពីវឌ្ឍនភាព បញ្ហាប្រឈម និងផែនការយុទ្ធសាស្ត្រ ក្នុងការអភិវឌ្ឍកំពង់ផែស្វយ័តភ្នំពេញ និងកំពង់ផែស្វយ័តក្រុងព្រះសីហនុ និង
- ❖ គណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាស្វែងយល់ និងសម្រង់ព័ត៌មានពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់ខ្លួន រួមមាន៖ ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ច វឌ្ឍនភាពការងារ និងបញ្ហាប្រឈមនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការអភិវឌ្ឍមូលដ្ឋាន ព្រមទាំងសំណូមពរនានា ដែលខេត្តបានជួបនាពេលកន្លងទៅ និងពេលបច្ចុប្បន្ន នៅសាលប្រជុំសាលាខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម។

### ៣-មុខងារតំណាង

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា៖

❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា បាន៖**

- អញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំ ចំនួន១៣លើក រួមមាន៖
  - អញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន៨លើក សម័យប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៥ ចំនួន៤លើក និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ ចំនួន១លើក។
- អនុញ្ញាតឱ្យភ្ញៀវជាតិ និងគណបក្សនយោបាយនៅកម្ពុជា ចូលជួបសម្តែងគារវកិច្ច និងទទួលអនុសាសន៍ ចំនួន៧លើក រួមមាន៖

  ១/ **ឯកឧត្តម សុក ហាច** ប្រធានគណបក្សឆន្ទៈខ្មែរ និងសមាជិកព្រឹទ្ធសភា ២រូបទៀត **ឯកឧត្តម សេង ម៉ារឌី** និង**ឯកឧត្តម គង់ មុនីកា**

  ២/ **ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ** សមាជិកព្រឹទ្ធសភា

  ៣/ **លោក** Pierre Tami (**សែន សិលា**) សហគ្រិនសង្គម

  ៤/ ក្រុមនិស្សិតជ័យលាភីអាហារូបករណ៍របស់រដ្ឋាភិបាលអូស្ត្រាលី ចំនួន១៨រូប

  ៥/ គណៈប្រតិភូសមាគមសិល្បករខ្មែរ

  ៦/ គណៈប្រតិភូក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដឹកនាំដោយ **លោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី** និង

  ៧/ និស្សិតជ័យលាភីអាហារូបករណ៍កម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សរបស់រដ្ឋាភិបាលជប៉ុន (JDS-២០២៣) ចំនួន២៥នាក់ និងជ័យលាភីអាហារូបករណ៍បន្តការសិក្សានៅសាធារណរដ្ឋឆែក ចំនួន១៥នាក់។
- អញ្ជើញដង្ហែ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា និងចូលរួមជាអធិបតីក្នុងពិធីនានា ចំនួន៣១លើក។

❖ **ឯកឧត្តម ឡោក់ សុខុន អតីតអនុប្រធានទី១ព្រឹទ្ធសភា បាន៖**

- អញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំ និងចូលរួមកិច្ចប្រជុំ ចំនួន២៥លើក រួមមាន៖
  - អញ្ជើញជាអធិបតីដឹកនាំបើកសម័យប្រជុំលើកទី១ព្រឹទ្ធសភា នីតិកាលទី៥។
  - អញ្ជើញដឹកនាំ និងចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន៦លើក។
  - អញ្ជើញដឹកនាំសម័យប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៥ ចំនួន១លើក និងកិច្ចប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ចំនួន១លើក និង
  - អញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំការងារសំខាន់ៗរបស់ព្រឹទ្ធសភា ចំនួន១៦លើក។
- អនុញ្ញាតឱ្យភ្ញៀវជាតិ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ចំនួន៤លើក រួមមាន៖

  ១/ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា**នៃព្រះរាជាណាចក្រកម្ពុជា

  ២/ **សម្តេចរាជបុត្រីព្រះអនុជ នរោត្តម អរុណរស្មី** សមាជិកព្រឹទ្ធសភា

  ៣/ **ឯកឧត្តម ម៉ម សារិន** ប្រធានក្រុមទីប្រឹក្សា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** និង

៤/ **ឯកឧត្តម គី តិច** ប្រធានក្រុមមេធាវីរាជរដ្ឋាភិបាល និងជាប្រធានក្រុមមេធាវីស្ម័គ្រចិត្ត **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា។**

- សកម្មភាពចុះមូលដ្ឋាន៖
  - អញ្ជើញចុះជួបសំណេះសំណាល និងសួរសុខទុក្ខអាជ្ញាធរមូលដ្ឋាន និងនាំយកអំណោយទេយ្យទាន និងបច្ច័យប្រគេនព្រះសង្ឃ តាជី យាយជី ចាស់ជរា និងប្រជាពលរដ្ឋ នៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តព្រៃវែង ខេត្តសៀមរាប ខេត្តមណ្ឌលគិរី ចំនួន ១១លើក។
- សកម្មភាពចូលរួមពិធីផ្សេងៗ៖
  - អញ្ជើញជាអធិបតីក្នុងពិធីបើក-បិទសិក្ខាសាលា និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗ ចំនួន៥៧លើក និង
  - អញ្ជើញជាអធិបតីក្នុងពិធីលៀងសាយភោជន៍ និងពិសាអាហារការងារជាមួយភ្ញៀវជាតិ និងអន្តរជាតិ ចំនួន៧លើក។

❖ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បាន៖

- អញ្ជើញជាគណៈអធិបតី ដឹកនាំ និងចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ ចំនួន៤២លើក រួមមាន៖
  - អញ្ជើញដឹកនាំ និងចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន១២លើក។
  - អញ្ជើញចូលរួមសម័យប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៥ ចំនួន៥លើក កិច្ចប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ ចំនួន២លើក និង
  - អញ្ជើញជាគណៈអធិបតីក្នុងសិក្ខាសាលា វេទិកា និងកិច្ចប្រជុំផ្ទៃក្នុង ចំនួន២៦លើក។
- សកម្មភាពចុះមូលដ្ឋាន៖
  - អញ្ជើញចុះជួបសំណេះសំណាល និងសួរសុខទុក្ខជាមួយអាជ្ញាធរមូលដ្ឋាន និងជាអធិបតីក្នុងពិធីសម្ពោធអគារសិក្សា ចំនួន៥លើក នៅខេត្តកំពង់ចាម ខេត្តសៀមរាប និងខេត្តត្បូងឃ្មុំ និង
  - ចាត់សមាជិកព្រឹទ្ធសភា ក្រុមការងារខុទ្ទកាល័យ និងទីប្រឹក្សាដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសាធារណរដ្ឋបារាំង ចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ និងពិនិត្យការដ្ឋានជួសជុលផ្លូវប្រវែង២,៧៥០ម៉ែត្រ ចំនួន៩លើក នៅខេត្តត្បូងឃ្មុំ ខេត្តកណ្តាល ខេត្តកំពង់ចាម និងខេត្តកំពង់ធំ។
- សកម្មភាពចូលរួមពិធីផ្សេងៗ៖
  - អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗ ចំនួន៤០លើក និង
  - អញ្ជើញជាអធិបតីក្នុងពិធីលៀងសាយភោជន៍ និងពិសាអាហារការងារជាមួយភ្ញៀវជាតិ និងអន្តរជាតិ ចំនួន១១លើក។

**❖ ឯកឧត្តមបណ្ឌិត ឆន់ ខឡុនា អនុប្រធានទី២ព្រឹទ្ធសភា បាន៖**

- អញ្ជើញដឹកនាំ និងចូលរួមកិច្ចប្រជុំនានា រួមមាន៖

- អញ្ជើញចូលរួមសម័យប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៥ ចំនួន១លើក។
- អញ្ជើញដឹកនាំកិច្ចប្រជុំជាមួយប្រធានគណៈកម្មការទាំង១០ព្រឹទ្ធសភា ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ និងក្រុមសមាជិកាព្រឹទ្ធសភា ដើម្បីពិនិត្យពិភាក្សាលើផែនការចុះបេសកកម្ម នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។
- អញ្ជើញដឹកនាំកិច្ចប្រជុំស្តីពី ការបែងចែកតួនាទី ភារកិច្ចរបស់សមាជិកខុទ្ទកាល័យអនុប្រធានទី២ព្រឹទ្ធសភា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា និង
- អញ្ជើញដឹកនាំកិច្ចប្រជុំជាមួយក្រុមប្រឹក្សាសាកលវិទ្យាធិការនៃកម្ពុជា(កសក) ដែលជាថ្នាក់ដឹកនាំគ្រឹះស្ថានឧត្តមសិក្សារដ្ឋ ចំនួន២២ ដើម្បីពិភាក្សាស្វែងយល់អំពីលទ្ធភាពសហការគ្នាដើម្បីជំរុញវិស័យអប់រំ ពិសេសការសិក្សាស្រាវជ្រាវ នៅវិមានព្រឹទ្ធសភា។

▪ សកម្មភាពចូលរួមពិធីផ្សេងៗ៖

- អញ្ជើញចូលរួមពិធីប្រកាសផ្ទេរ និងចូលកាន់តំណែងអគ្គនាយកព័ត៌មាន និងទំនាក់ទំនងសាធារណៈ និងអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ក្រោមអធិបតីភាពរបស់ **ឯកឧត្តម អ៊ុច បូររិទ្ធ ប្រធានស្តីទីព្រឹទ្ធសភា** នៅវិមានព្រឹទ្ធសភា។
- អញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងព្រឹត្តិការណ៍ការសម្តែងសិល្បៈពិសេស ក្រោមប្រធានបទ " ពាក្យសច្ចាពណ៌មាស " ដែលជាផ្នែកមួយរបស់ឆ្នាំនៃការផ្លាស់ប្តូរប្រជាជន និងប្រជាជនចិន-កម្ពុជា ឆ្នាំ២០២៤ នៅសាលមហោស្រពចតុមុខ រាជធានីភ្នំពេញ និង
- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗ ចំនួន៤លើក។

❖ **សមាជិក សមាជិកាព្រឹទ្ធសភា បាន៖**

▪ អញ្ជើញចូលរួមសិក្ខាសាលាថ្នាក់តំបន់ស្តីពី " ស្ត្រី សន្តិភាព និងសន្តិសុខ៖ បច្ចេកទេស និងវិធីសាស្ត្រចរចា និងសម្រុះសម្រួលក្នុងក្របខណ្ឌសភា " ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា**នៃព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំបាយ័ន វិមានរដ្ឋសភា។

▪ អញ្ជើញចូលរួមសិក្ខាសាលាស្តីពី " ការកសាងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០២៥ " រៀបចំដោយគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃរដ្ឋសភា នៅសាលសន្និសីទបាយ័ន វិមានរដ្ឋសភា។

▪ អញ្ជើញចូលរួមសិក្ខាសាលាស្តីពី " កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលជូនតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភា " នៅសណ្ឋាគារសុខាភ្នំពេញ រាជធានីភ្នំពេញ។

▪ អញ្ជើញចូលរួមពិធីបើក និងបិទសិក្ខាសាលាការផ្លាស់ប្តូរព័ត៌មានក្នុងស្ថាប័នសភាស្តីពីតួនាទី និងសមត្ថកិច្ចក្នុងសេវាកម្មស្រាវជ្រាវនៅសភា និងពិធីបំពាក់គ្រឿងឥស្សរិយយស (Ordre de la Pléiade) របស់សភាប្រើភាសាបារាំង ជូនសមាជិកសភាកម្ពុជា និងអ្នកសារព័ត៌មាន ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ប្រាក់ សុខុន អនុប្រធានទី១ព្រឹទ្ធសភា**

ប្រធានក្រុមសភាជាតិកម្ពុជា និងជាអនុប្រធានសភាប្រើភាសាបារាំង (APF) នៅសាលខាងជើង វិមានព្រឹទ្ធសភា។

- អញ្ជើញចូលរួមវេទិកាពិសេសស្តីពី " សន្តិភាពសម្រាប់មនុស្សជាតិ និងភពផែនដី " និងកិច្ចពិភាក្សាស្តីពី " ធម្មនុញ្ញសន្តិភាព ដើម្បីមនុស្សជាតិ និងភពផែនដី " នៅសណ្ឋាគារ Raffles Grand Hotel d'Angkor ខេត្តសៀមរាប។
- អញ្ជើញចូលរួមជាអធិបតីក្នុងពិធីបើកវេទិកាជាតិស្តីពី " ស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច " ក្រោមប្រធានបទ " ភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅរដ្ឋបាលមូលដ្ឋាន " ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៅសណ្ឋាគារសាន់&មូន រីវើសាយ រាជធានីភ្នំពេញ។
- អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមបេសកកម្មកម្មសិក្សាអាស៊ី(AMS) របស់សាធារណរដ្ឋបារាំង ទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋរស់នៅខេត្តព្រៃវែង ខេត្តកំពត ខេត្តកំពង់ស្ពឺ ខេត្តស្វាយរៀង ខេត្តតាកែវ ខេត្តសៀមរាប ខេត្តកណ្តាល និងខេត្តកំពង់ធំ។
- អញ្ជើញនាំយកអំណោយជាឱសថ ចំនួន១១មុខ ដែលជាជំនួយមនុស្សធម៌របស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកល (Global Life Sharing) នៃសាធារណរដ្ឋកូរ៉េ ប្រគល់ជូនដល់មន្ទីរពេទ្យបង្អែកស្រុកតំបែរ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ស្រុកស្ទឹងត្រង់ ស្រុកចំការលើ ខេត្តកំពង់ចាម។
- អញ្ជើញចូលរួមស្តាប់បទបង្ហាញរបស់ **ឯកឧត្តម M.Vincent Éblé** សមាជិកព្រឹទ្ធសភាប្រចាំតំបន់ Seine-et-Marne (Île-de-France) និងជាប្រធានក្រុមអន្តរសភាមិត្តភាពបារាំង-កម្ពុជា ស្តីពី " បទពិសោធន៍របស់ព្រឹទ្ធសភាបារាំង " នៅវិមានព្រឹទ្ធសភា។
- អញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងសន្និសីទថ្នាក់ជាតិស្តីពី គោលនយោបាយគ្រឿងស្រវឹង នៅរាជធានីភ្នំពេញ។
- អញ្ជើញចូលរួមប្រជុំពិភាក្សាការងារជាមួយ **ឯកឧត្តម គី តិច** ប្រធានក្រុមមេធាវីរាជរដ្ឋាភិបាល និងជាប្រធានក្រុមមេធាវីស្ម័គ្រចិត្ត **សម្តេចតេជោសែន** ដើម្បីពិភាក្សាលើការបន្តអនុស្សរណៈនៃការយោគយល់គ្នារវាងគណៈកម្មការទី១ព្រឹទ្ធសភា ជាមួយក្រុមមេធាវីស្ម័គ្រចិត្ត **សម្តេចតេជោសែន** នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។
- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីមីទ្ទិញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៦ ទិវាកំណើតរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា ២ ធ្នូ ១៩៧៨ - ២ ធ្នូ ២០២៤ នៅសាលសន្និសីទចតុម្មុខ រាជធានីភ្នំពេញ។
- អញ្ជើញជាអធិបតីក្នុងវេទិកាពិគ្រោះយោបល់ស្តីពី បញ្ហាប្រឈម និងសំណូមពរ នៅភូមិភាគទី១ រាជធានីភ្នំពេញ ជាមួយតំណាងក្រសួងមហាផ្ទៃ តំណាងក្រសួងសេដ្ឋកិច្ច និង

ហិរញ្ញវត្ថុ ថ្នាក់ដឹកនាំរាជធានីភ្នំពេញ ថ្នាក់ដឹកនាំខណ្ឌ ប្រធានក្រុមប្រឹក្សាសង្កាត់ និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាល ដែលមានសមាសភាពចូលរួម ចំនួន៣០០នាក់។

- អញ្ជើញជាគ្រូឧទ្ទេសនាមស្តីពី " សភាពការណ៍កម្ពុជា និងបណ្តាភារកិច្ចចំពោះមុខ " ជូនដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សាក្រុង ស្រុក និងមន្រ្តីជំនាញពាក់ព័ន្ធ សរុបចំនួន ៧០នាក់ នៅស្រុកស្រែអំបិល ខេត្តកោះកុង។
- អញ្ជើញធ្វើបទបង្ហាញស្តីពី រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ព្រឹទ្ធសភា ជូនដល់បុគ្គលិក សាស្ត្រាចារ្យ និងនិស្សិត មកពីវិទ្យាស្ថានវ៉ាន់ដា សាកលវិទ្យាល័យជាតិខេត្តបាត់ដំបង សាកលវិទ្យាល័យជាតិគ្រប់គ្រង សាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេយសៀ ( South-East Asia ) ខេត្តសៀមរាប នៅវិមានព្រឹទ្ធសភា។
- អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីផ្សេងៗ **ចំនួន២១លើក** ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា នៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តតាកែវ និងខេត្តស្វាយរៀង។
- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ **ចំនួន៣៤លើក** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា នៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តកំពត ខេត្តព្រះសីហនុ ខេត្តកែប ខេត្តមណ្ឌលគិរី ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ។
- ក្រុមសមាជិក សមាជិកាព្រឹទ្ធសភា ប្រចាំភូមិភាគទាំង៨ ចូលរួមប្រជុំដើម្បីពិនិត្យ និងពិភាក្សាលើការងារសំខាន់ៗ រួមមាន៖ សេចក្តីព្រាងផែនការយុទ្ធសាស្ត្ររបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ រយៈពេល ៦ឆ្នាំ( ២០២៤-២០៣០ ) សេចក្តីព្រាងផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៤ និងពិនិត្យឆ្លងសេចក្តីសម្រេច តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ក្រុមនានា។
- សមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ បានប្រជុំពិនិត្យ និងសម្រេចយោបល់លើផែនការយុទ្ធសាស្ត្រ ៦ឆ្នាំ (២០២៤-២០៣០) ផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៤ និងការងារផ្សេងៗ នៅសាលប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា។
- ក្រុមសមាជិកព្រឹទ្ធសភា បានរៀបចំវេទិកាសាធារណៈ ចំនួន៣លើក ស្តីពី តម្រូវការជាក់ស្តែង កង្វល់ បញ្ហាប្រឈមនានា របស់ប្រជាពលរដ្ឋ នៅរាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ ខេត្តព្រៃវែង និងខេត្តស្វាយរៀង និង
- ក្រុមសមាជិកាព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី ចំនួន១១៣នាក់ នៅខេត្តកំពង់ធំ។

❖ ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ជួបពិភាក្សាការងារជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់អាជ្ញាធរមូលដ្ឋាន ស្វែងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខ

សណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអនុវត្តគោលនយោបាយនានា ពិនិត្យការដ្ឋាន ជីក ស្តារ ប្រព័ន្ធធារាសាស្ត្រ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានី និងតាមបណ្តាខេត្ត ក្រុងនានា **ចំនួន៨៥០លើក** ព្រមទាំងបានអញ្ជើញជាគណៈអធិបតីក្នុងពិធីសម្ពោធសមិទ្ធផលនានា និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗ **ចំនួន១,១៣៧លើក**។

- សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

❖ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បាន៖

- អញ្ជើញចូលរួមសម័យប្រជុំដំបូងព្រឹទ្ធសភានីតិកាលទី៥ កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន១០លើក សម័យប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៥ ចំនួន៧លើក និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ ចំនួន២លើក។
- អញ្ជើញចូលរួមអមដំណើរថ្នាក់ដឹកនាំព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារនៅមូលដ្ឋាន នាំយកទេយ្យទាន និងបច្ច័យប្រគេនព្រះសង្ឃ ចូលរួមគោរពវិញ្ញាណក្ខន្ធ និងពិធីផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ចំនួន១៥០លើក។
- អនុញ្ញាតឱ្យភ្ញៀវជាតិ ចូលជួបពិភាក្សាការងារ ចំនួន៤លើក។
- អញ្ជើញជួបសំណេះសំណាល និងផ្តល់អនុសាសន៍ដល់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលទៅចូលរួមវគ្គបណ្តុះបណ្តាល នៅសាធារណរដ្ឋប្រជាមានិតចិន និងសាធារណរដ្ឋឥណ្ឌា ចំនួន២លើក។
- អញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមេសា ដល់ខែធ្នូ ឆ្នាំ២០២៤ និងទិសដៅការងារបន្ត ចំនួន៩លើក។
- អញ្ជើញប្រគល់ខោអាវកីឡាបាល់ទាត់ដែលជាអំណោយរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនក្រុមបាល់ទាត់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាវ័យចំណាស់។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា បាន៖

- អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន១០លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៥ ចំនួន៥លើក។
- អញ្ជើញនាំយកថវិកាឧបត្ថម្ភរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា** ប្រគល់ជូនគណៈកម្មាធិការជាតិរៀបចំព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក នៅមុខព្រះបរមរាជវាំង។
- អញ្ជើញចូលរួមអមដំណើរថ្នាក់ដឹកនាំព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារនៅមូលដ្ឋាន នាំយកទេយ្យទាន និងបច្ច័យប្រគេនព្រះសង្ឃ ចូលរួមគោរពវិញ្ញាណក្ខន្ធ និងពិធីផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ចំនួន១៨លើក និង
- អញ្ជើញចូលរួមកិច្ចប្រជុំ សន្និសីទ សិក្ខាសាលា និងពិធីផ្សេងៗ ចំនួន៧២លើក។

- ❖ **ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានៈ
  - អញ្ជើញចូលរួមអមដំណើរថ្នាក់ដឹកនាំព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារនៅមូលដ្ឋាន នាំយកទេយ្យទាន និងបច្ច័យប្រគេនព្រះសង្ឃ ចូលរួមគោរពវិញ្ញាណក្ខន្ធ និងពិធីផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ចំនួន៤លើក និង
  - អញ្ជើញចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ ចំនួន១៤លើក។
- ❖ **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានៈ
  - អញ្ជើញចូលរួមអមដំណើរថ្នាក់ដឹកនាំព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារនៅមូលដ្ឋាន នាំយកទេយ្យទាន និងបច្ច័យប្រគេនព្រះសង្ឃ ចូលរួមគោរពវិញ្ញាណក្ខន្ធ និងពិធីផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ចំនួន១៦លើក។
  - អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមបេសកកម្មមនុស្សធម៌កម្ពុជា(AMH) របស់សាធារណរដ្ឋបារាំង ចុះពិនិត្យ និងព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ចំនួន១៣លើក ព្រមទាំងបានប្រគល់រទេះរុញ ចំនួន២គ្រឿង ដែលជាអំណោយរបស់ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា ជូនប្រជាពលរដ្ឋដែលពិការដោយសារជំងឺលើសឈាម និង
  - អញ្ជើញចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ ចំនួន២០លើក។

- បានរៀបចំចាត់ចែងបញ្ជូនសារលិខិតថ្វាយព្រះពរ និងលិខិតជូនពរ លិខិតអបអរសាទរ លិខិតថ្លែងអំណរគុណ របស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ និងគោរពជូន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា និងឥស្សរជនជាន់ខ្ពស់ជាតិ-អន្តរជាតិ ព្រមទាំងថ្នាក់ដឹកនាំ តាមក្រសួង ស្ថាប័ននានា ក្នុងឱកាសនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវស្សា ចម្រើនជន្មាយុ ពិធីខួបកំណើត ពិធីទទួលគោរមងារ ពិធីទទួលគ្រឿងឥស្សរិយយស ពិធីបុណ្យប្រពៃណីជាតិ និងអន្តរជាតិផ្សេងៗ។
- បានរៀបចំជូនគណៈប្រតិភូព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចូលរួមក្នុងពិធីគោរពវិញ្ញាណក្ខន្ធ ពិធីបញ្ចុះសព និងពិធីបូជាសព ព្រមទាំងបានចាត់ចែងបញ្ជូនសារលិខិតរំលែកទុក្ខជូនក្រុមគ្រួសារឥស្សរជនជាន់ខ្ពស់ជាតិ-អន្តរជាតិ និងថ្នាក់ដឹកនាំតាមក្រសួង ស្ថាប័ននានា។
- បានរៀបចំទទួលដំណើរទស្សនកិច្ច និងធ្វើបទបង្ហាញស្តីពី " រចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា " និង " នីតិវិធីនៃការបង្កើតច្បាប់កម្ពុជា " ជូនបុគ្គលិក សាស្ត្រាចារ្យ សមណនិស្សិត និងនិស្សិតនៃសាកលវិទ្យាល័យ និងវិទ្យាស្ថាននានា ចំនួន៦លើក។
- បានរៀបចំតុបតែងលម្អសង្ក្រាន្ត ការសម្តែងរបាំត្រុដិ របាំជូនពរ កម្មវិធីលេងល្បែងប្រជាប្រិយខ្មែរ ព្រមទាំងរៀបចំពិធីសូត្រមន្តប្រោះព្រំ សិរីសួស្តី ជ័យមង្គល និងអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប្រាក់ សុខុន** អនុប្រធានទី១ព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។

- បានរៀបចំសិក្ខាសាលាស្ដីពី ការផ្ដល់ព័ត៌មានបឋមអំពី តួនាទី ភារកិច្ច សមត្ថកិច្ច និងយន្តការទាំងឡាយរបស់ព្រឹទ្ធសភា សម្រាប់សមាជិក សមាជិកាព្រឹទ្ធសភា នីតិកាលទី៥ ។
- បានរៀបចំពិធីសំណេះសំណាល និងពិសាអាហារសាមគ្គីជាមួយនិវត្តជន និងមន្ត្រីរាជការវ័យចំណាស់នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងឱកាសទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិលើកទី២៦ ( ១ តុលា ២០២៤ ) ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ។
- បានប្រគល់ថវិកាឧបត្ថម្ភរបស់ព្រឹទ្ធសភា និងឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា ជូនកាកបាទក្រហមកម្ពុជា ក្នុងឱកាសខួបលើកទី១៦១ នៃទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ ឧសភា ២០២៤។
- បាននាំយកថវិកា និងអំណោយមួយចំនួនរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី៤៦ ទិវាកំណើតរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា ២ ធ្នូ ១៩៧៨ - ២ ធ្នូ ២០២៤។
- បានប្រគល់ថវិកាបរិច្ចាគដោយស្ម័គ្រចិត្តរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំ មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូន " មូលនិធិគន្ធបុប្ផាកម្ពុជា " សម្រាប់ឆ្នាំ២០២៤ ចំនួន២លើក។
- បានរៀបចំគ្រឿងសក្ការបូជាសម្រាប់រាប់បាត្រប្រគេនព្រះសង្ឃ ចំនួន៨០កញ្ចប់ ក្នុងពិធីបុណ្យវិសាខបូជា និងអំណោយ ចំនួន៣០កញ្ចប់ ជូនគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិ។
- បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅ នៅបណ្ណាល័យព្រឹទ្ធសភា ចំនួន១៥៧នាក់ និង
- បានទទួលពាក្យបណ្ដឹង ចំនួន៣១បណ្ដឹង ធ្វើកំណត់បង្ហាញពាក្យបណ្ដឹង ចំនួន២៤បណ្ដឹង បញ្ជូនពាក្យបណ្ដឹងទៅក្រសួង ខេត្ត ស្ថាប័នពាក់ព័ន្ធ ចំនួន១៨បណ្ដឹង តម្កល់ទុកមិនចាត់ការ ចំនួន៦បណ្ដឹង កំពុងពិនិត្យសិក្សា ចំនួន៧បណ្ដឹង ផ្ដល់ព័ត៌មានទៅម្ចាស់បណ្ដឹង ចំនួន២៤បណ្ដឹង ទទួលលិខិតឆ្លើយតបពីការដោះស្រាយ ពីស្ថាប័នពាក់ព័ន្ធ ចំនួន៤បណ្ដឹង បានទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន៦បណ្ដឹង។

## ៤-មុខងារសហប្រតិបត្តិការអន្តរជាតិ

- បានរៀបចំចាត់ចែង និងផ្ដល់សេវាជូនប្រមុខរដ្ឋស្ដីទីនៃព្រះរាជាណាចក្រកម្ពុជា ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា៖
  - ❖ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** ក្នុងតួនាទីជាប្រមុខរដ្ឋស្ដីទីនៃព្រះរាជាណាចក្រកម្ពុជា បានទទួលសារតាំង ចំនួន២លើក នៅវិមានព្រឹទ្ធសភា រួមមាន៖
    - **ឯកឧត្តម ដេរេក យីប** ( Derek Yip ) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសអូស្ត្រាលី ប្រចាំព្រះរាជាណាចក្រកម្ពុជា និង
    - **ឯកឧត្តម កាណាត់ ទូមីសហ្ស** ( Kanat Tumysh ) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋកាហ្សាក់ស្ថាន ប្រចាំព្រះរាជាណាចក្រកម្ពុជា។

❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា បាន៖**

- អនុញ្ញាតឱ្យភ្ញៀវអន្តរជាតិជួបពិភាក្សាការងារតាមប្រព័ន្ធនិម្មិត និងចូលជួបសម្តែងការគួរសម ពិភាក្សាការងារ និងជម្រាបលា ចំនួន៣៥លើក រួមមាន៖

  ១/ ប្រធានរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម

  ២/ ប្រធានសភាអ៊ុយក្រែន

  ៣/ ប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

  ៤/ ប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

  ៥/ នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

  ៦/ ប្រធានក្រុមប្រឹក្សារដ្ឋបាលរដ្ឋនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា

  ៧/ រដ្ឋមន្ត្រីការពារជាតិសហរដ្ឋអាម៉េរិក

  ៨/ រដ្ឋមន្ត្រីក្រសួងការពារជាតិជប៉ុន

  ៩/ រដ្ឋមន្ត្រីការបរទេសជប៉ុន

  ១០/ រដ្ឋមន្ត្រីការពារប្រទេសនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

  ១១/ រដ្ឋមន្ត្រីការពារជាតិ និងជាប្រធានាធិបតីជាប់ឆ្នោតនៃសាធារណរដ្ឋឥណ្ឌូណេស៊ី

  ១២/រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ និងជាបេសកជនពិសេសរបស់ប្រធានក្រុមប្រឹក្សារដ្ឋបាលរដ្ឋនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា

  ១៣/អតីតអនុរដ្ឋមន្ត្រីការបរទេសជប៉ុន និងជាអតីតឯកអគ្គរាជទូតពិសេសទទួលបន្ទុកកសាងសន្តិភាពជប៉ុន

  ១៤/ អនុប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនចិន

  ១៥/ សមាជិកព្រឹទ្ធសភាប្រចាំតំបន់ Seine-et-Marne (Île-de-France) និងជាប្រធានក្រុមអន្តរសភាមិត្តភាពបារាំង-កម្ពុជា

  ១៦/ ប្រធានគណបក្ស Komeito និងជាសមាជិកព្រឹទ្ធសភាជប៉ុន

  ១៧/ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាស៊ាន

  ១៨/ អគ្គលេខាធិការរងអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកទ្រទ្រង់ប្រតិបត្តិការរក្សាសន្តិភាព

  ១៩/ នាយកទីភ្នាក់ងារស៊ើបការណ៍មជ្ឈិម (CIA) របស់សហរដ្ឋអាម៉េក

  ២០/ ប្រធាន និងនាយកប្រតិបត្តិមូលនិធិអាស៊ី (Asia Foundation)

  ២១/ ប្រធានតំណាងមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា

  ២២/ ប្រធានវិទ្យាស្ថានយុទ្ធសាស្ត្រ KSI ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក

  ២៣/បេសកជនពិសេសរបស់រដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការមីយ៉ាន់ម៉ា ដើម្បីគាំទ្រដល់កិច្ចការអន្តរជាតិ

  ២៤/សមាជិកគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន និងជាប្រធានវិទ្យាស្ថានប្រវត្តិសាស្ត្រ និងអក្សរសាស្ត្រនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន

២៥/ ប្រធានសមាគមជប៉ុន-កម្ពុជា
២៦/ ប្រធានវណសិប្បអភិវឌ្ឍន៍ជាតិឡាវ
២៧/ តំណាងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិប្រចាំកម្ពុជា
២៨/ សមាជិកគណៈលេខាធិការមជ្ឈិមបក្សប្រធានគណៈទាក់ទងបរទេសនៃគណៈកម្មា-ធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម
២៩/ ប្រធានប្រតិបត្តិ និងស្ថាបនិកក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុប្លុកឆេនអាម៉េរិក
៣០/ បេសកជនពិសេសរដ្ឋាភិបាលជប៉ុន
៣១/ ទីប្រឹក្សាសន្តិសុខជាតិ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានសន្តិសុខជាតិជប៉ុន
៣២/ អភិបាលខេត្តឃ្យុងសាងប៊ុកដូ សាធារណរដ្ឋកូរ៉េ
៣៣/ តំណាងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) នៃធនាគារពិភពលោក
៣៤/គណៈប្រតិភូថ្នាក់ដឹកនាំក្រុមហ៊ុន តូយ៉ូតា ស៊ុយស៊ូ គ្រុប (Toyota Tsusho Corporation) និង
៣៥/ព្រះសង្ឃខ្មែរក្រោម ចំនួន៦ព្រះអង្គនៃខេត្តត្រាវិញ សាធារណរដ្ឋសង្គមនិយមវៀតណាម។

- អនុញ្ញាតឱ្យថ្នាក់ដឹកនាំនៃបណ្តាគណបក្សនយោបាយនៅអាស៊ី (ICAPP) លើកទី១២ ជួបសម្តែងការគួរសម ចំនួន៤គណៈប្រតិភូ រួមមាន៖

១/ ប្រធានអង្គការអ្នកប្រជាធិបតេយ្យនិយមកណ្តាលអន្តរជាតិ CDI-IDC
២/ អនុប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
៣/ប្រធានគណបក្សសហភាពសាមគ្គីភាព និងអភិវឌ្ឍន៍នៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា និង
៤/ អនុប្រធានគណបក្សយុត្តិធម៌ និងអភិវឌ្ឍន៍ (AK Parti) នៃសាធារណរដ្ឋតួកគីយ៉េ។

- អនុញ្ញាតឱ្យបណ្តាថ្នាក់ដឹកនាំសភាអន្តរជាតិដើម្បីភាពអត់ឱន និងសន្តិភាព លើកទី១១ (IPTP-11) ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ ចូលជួបសម្តែងការគួរសម ចំនួន៣គណៈប្រតិភូ រួមមាន៖

១/ ប្រធានរដ្ឋសភានៃសាធារណរដ្ឋសហព័ន្ធប្រជាធិបតេយ្យនេប៉ាល់ និងប្រធានរដ្ឋសភានៃសាធារណរដ្ឋកេនយ៉ា
២/ ស្ថាបនិក និងជាប្រធានក្រុមប្រឹក្សាសាកលដើម្បីភាពអត់ឱន និងសន្តិភាព និង
៣/ ប្រធានសមាគមអន្តរជាតិនៃសមាជិកសភាដើម្បីសន្តិភាព (IAPP)។

- ទទួលជួបឯកអគ្គរាជទូត និងឯកអគ្គរដ្ឋទូត ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមាននិវេសនដ្ឋាន នៅរាជធានីភ្នំពេញ ចំនួន១៨រូប ដើម្បីសម្តែងការគួរសម ពិភាក្សាការងារ និងជម្រាបលា នៅវិមានព្រឹទ្ធសភា រួមមាន៖

១/ ឯកអគ្គរដ្ឋទូតនៃសហភាពអឺរ៉ុប
២/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋបារាំង

៣/ ឯកអគ្គរាជទូតនៃចក្រភពអង់គ្លេស

៤/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាមានិតចិន

៥/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋកូរ៉េ

៦/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ

៧/ ឯកអគ្គរដ្ឋទូតនៃសហព័ន្ធរុស្ស៊ី

៨/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

៩/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋតួកគីយ៉េ

១០/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឆែក

១១/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥណ្ឌា

១២/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋគុយបា

១៣/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា

១៤/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥណ្ឌូណេស៊ី

១៥/ ឯកអគ្គរាជទូតនៃប្រទេសម៉ាឡេស៊ី

១៦/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋហ្វីលីពីន

១៧/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ និង

១៨/ ភារធារីស្តីទីនៃសហរដ្ឋអាម៉េរិក។

- ទទួលជួបឯកអគ្គរាជទូត និងឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមាននិវេសនដ្ឋាន នៅរាជធានីភ្នំពេញ ចប់អាណត្តិបេសកកម្មការទូត ចំនួន៤រូប ដើម្បីសម្តែងការគួរសម និងជម្រាបលា រួមមាន៖

  ១/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាមានិតចិន

  ២/ ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រថៃឡង់ដ៏

  ៣/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥណ្ឌា និង

  ៤/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

- ទទួលជួបឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមាននិវេសនដ្ឋាន នៅក្រៅប្រទេស ចំនួន៤រូប ដើម្បីសម្តែងការគួរសម ពិភាក្សាការងារ និងជម្រាបលា នៅវិមានព្រឹទ្ធសភា រួមមាន៖

  ១/ ឯកអគ្គរដ្ឋទូតនៃរដ្ឋកាតា

  ២/ ឯកអគ្គរដ្ឋទូតនៃប្រទេសកាណាដា

  ៣/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស និង

  ៤/ ឯកអគ្គរដ្ឋទូតនៃប្រទេសអ៊ុយក្រែន។

❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** បានអញ្ជើញបំពេញការងារនៅក្រៅប្រទេស ចំនួន៤លើក រួមមាន៖

- អញ្ជើញដឹកនាំគណៈប្រតិភូទៅចូលរួមពិធីគោរពវិញ្ញាណក្ខន្ធ **ឯកឧត្តម ង្វៀន ហ្វូចុង** (Nguyen Phu Trong) អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម នៅទីក្រុងហាណូយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដោយក្នុងឱកាសនោះ **សម្តេចតេជោ ប្រធានព្រឹទ្ធសភា** បានអញ្ជើញជួបពិភាក្សាការងារជាមួយៈ
  - **ឯកឧត្តម តូ ឡឹម** ប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។
  - **ឯកឧត្តម ផាម មិញជិញ** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។
  - **ឯកឧត្តម លឿង គឿង** សមាជិកការិយាល័យនយោបាយប្រចាំការគណៈលេខាបក្សកុម្មុយនីស្តវៀតណាម និង
  - **ឯកឧត្តម ជិន ថាញ់មិន** ប្រធានរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម។
- អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញចូលរួម " វេទិកាចំណេះដឹងពិភពលោកលើកទី២៥ " ក្រោមមូលបទ " ដំណើរឆ្ពោះទៅរកសហត្ថិភាព " នៅសាធារណរដ្ឋកូរ៉េ ដោយក្នុងឱកាសនោះ **សម្តេចតេជោ** បានអញ្ជើញពិភាក្សាការងារ និងចូលរួមក្នុងពិធីផ្សេងៗ ចំនួន១៨លើក។
- អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា បំពេញទស្សនកិច្ចមិត្តភាព និងជាផ្លូវការ នៅសាធារណរដ្ឋប្រជាមានិតចិន ដោយក្នុងឱកាសនោះ **សម្តេចតេជោ** បានអញ្ជើញជួបពិភាក្សាការងារ និងចូលរួមក្នុងពិធីផ្សេងៗ ចំនួន៥លើក និង
- អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា បំពេញទស្សនកិច្ចផ្លូវការ នៅព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត រដ្ឋកាតា សាធារណរដ្ឋតួកគីយ៉េ និងប្រទេសអេមីរ៉ាតអារ៉ាប់រួម ដោយក្នុងឱកាសនោះ **សម្តេចតេជោ** បានអញ្ជើញជួបពិភាក្សាការងារ និងចូលរួមក្នុងពិធីផ្សេងៗ ចំនួន១៧លើក។

❖ **ឯកឧត្តម ប្រាក់ សុខុន អតីតអនុប្រធានទី១ព្រឹទ្ធសភា បានៈ**

- អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា បំពេញទស្សនកិច្ចការងារ នៅព្រឹទ្ធសភានៃសាធារណរដ្ឋបារាំង និងសភាតំណាងរាស្ត្រនៃបូរីក្សេត្រលុចសំបួ។
- អនុញ្ញាតឱ្យភ្ញៀវអន្តរជាតិ និងឯកអគ្គរដ្ឋទូតនៃបណ្តាប្រទេសនានា ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ចំនួន១៩លើក នៅវិមានព្រឹទ្ធសភារួមមានៈ

  ១/ **ឯកឧត្តម យូ កូកូ ឡាំង** (U Koko Hlaing) រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ និងជាបេសកជនពិសេសរបស់ប្រធានក្រុមប្រឹក្សារដ្ឋបាលរដ្ឋនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា

  ២/ **ឯកឧត្តម វ៉ាឡាសៃ ឡេងសាវ៉ាត់** អនុប្រធានគណៈទាក់ទងបរទេសមជ្ឈិមបក្សប្រជាជនបដិវត្តន៍ឡាវ

  ៣/ **លោកជំទាវ រ៉េតណូ អិល.ភី.ម៉ារស៊ូឌី** (Retno L.P Marsudi) រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋឥណ្ឌូណេស៊ី

៤/ **ឯកឧត្តម ចាវ ស៊ីចុង** ឧបការីរដ្ឋមន្ត្រីក្រសួងទំនាក់ទំនងអន្តរជាតិនៃគណបក្សកុម្មុយនីសចិន

៥/ អនុប្រធានសភាក្រុមប្រឹក្សានយោបាយចិនទី១៣ និងជាប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមនៃសភាប្រឹក្សានយោបាយចិន

៦/ **ឯកឧត្តម ឈី ឈីងសាន** (Qu Qingshan) សមាជិកគណៈកម្មាធិការមជ្ឈិមបក្ស និងជាប្រធានវិទ្យាស្ថានប្រវត្តិសាស្ត្របក្ស និងអក្សរសាស្ត្រនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន

៧/ ឧបការីរដ្ឋមន្ត្រីក្រសួងទំនាក់ទំនងអន្តរជាតិមជ្ឈិមបក្សកុម្មុយនីស្តចិន

៨/ **លោកស្រី នីណូ ប៊ូចាសវីលី** (Nino Bujiashvili) ប្រធាននាយកដ្ឋានជំនាញកិច្ចការអន្តរជាតិនៃសភា G'eorgie

៩/ អគ្គលេខាធិការរងអង្គការសហប្រជាជាតិ

១០/ នាយកទទួលបន្ទុករៀបចំផែនការ គោលនយោបាយនៃក្រសួងការបរទេសអាម៉េរិក

១១/ អភិបាលខេត្តយ្យូសាងប៊ុកដូនៃសាធារណរដ្ឋកូរ៉េ

១២/**ឯកឧត្តម វ៉ាង វិនពីន** (Wang Wenbin) ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាមានិតចិន

១៣/ **ឯកឧត្តម អឺមេនេជីលដូ កូប៉ា ឡូប៉េស** (Ermenegildo Kupa Lopes) ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ

១៤/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋតួកគីយ៉េ

១៥/ ឯកអគ្គរដ្ឋទូតនៃប្រតិភូសហភាពអឺរ៉ុប

១៦/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឆែក

១៧/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋគុយបា

១៨/ ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំអាស៊ាន និង

១៩/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥណ្ឌូណេស៊ី។

- **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា បាន៖**
  - អញ្ជើញដឹកនាំ និងចូលរួមកិច្ចប្រជុំអន្តរជាតិនានា រួមមាន៖
    - ដឹកនាំកិច្ចប្រជុំរួមជាមួយ **ឯកឧត្តមបណ្ឌិត ចែម វីឡា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា និង**ឯកឧត្តម សួស យ៉ារ៉ា** ប្រធានគណៈកម្មការទី៥ រដ្ឋសភា ស្តីពី លទ្ធភាពនៃការអញ្ជើញចូលរួមរបស់ **សម្តេចតេជោ** ក្នុងវេទិកាអន្តរបក្សអន្តរជាតិ " BRICS បូក/ការតភ្ជាប់ " នៅទីក្រុងវ្លាឌីវ៉ូស្តុក សហព័ន្ធរុស្ស៊ី។
    - អញ្ជើញជាសហប្រធានរួមគ្នាជាមួយ **ឯកឧត្តម ប្រាក់ សុខុន អនុប្រធានទី១ព្រឹទ្ធសភា** ដឹកនាំកិច្ចប្រជុំក្រុមប្រតិភូ ដើម្បីត្រៀមចូលរួមមហាសន្និបាតលើកទី៤៩ នៃសភាប្រើ

ភាសាបារាំង (APF) នៅទីក្រុងមុងរ៉េអាល់ ប្រទេសកាណាដា។

- អញ្ជើញដឹកនាំកិច្ចប្រជុំនៃសមាជិកគណៈប្រតិភូកម្ពុជាទទួលបន្ទុកការងារសហភាពអន្តរសភា (IPU) ដើម្បីពិនិត្យលើវឌ្ឍនភាព និងការត្រៀមលក្ខណៈចូលរួមសន្និបាតលើកទី១៤៩ នៃសហភាពអន្តរសភា និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស និង
- អញ្ជើញចូលរួមសម័យប្រជុំពេញអង្គ IPTP លើកទី១១ នៅសណ្ឋាគារសុខាភ្នំពេញ ដោយមានអ្នកចូលរួមសរុបចំនួន១៩៧នាក់ មកពី៥៣ប្រទេស។

▪ អនុញ្ញាតឱ្យភ្ញៀវអន្តរជាតិ អង្គការអន្តរជាតិ និងឯកអគ្គរដ្ឋទូតនៃបណ្តាប្រទេសនានាប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ចំនួន១៣លើក រួមមាន៖

១/ ប្រធានទីភ្នាក់ងារកិច្ចការនីតិប្បញ្ញត្តិប្រចាំតំបន់ សភាតំណាងតំបន់នៃសាធារណរដ្ឋឥណ្ឌូណេស៊ី

២/ ប្រធានសមាគមបេសកកម្មកម្មសិក្សាអាស៊ី

៣/ ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកល

៤/ អនុប្រធានសភាប្រឹក្សានយោបាយប្រជាជនចិននៃសាធារណរដ្ឋប្រជាមានិតចិន

៥/ សមាជិកស្ថាបនិកសភាពាណិជ្ជកម្មត្រកូលលីនពិភពលោក

៦/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋតួកគីយ៉េ

៧/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឆែក

៨/ ឯកអគ្គរដ្ឋទូតនៃសហរដ្ឋអាម៉េរិក

៩/ ឯកអគ្គរដ្ឋទូតនៃប្រតិភូសហភាពអឺរ៉ុប

១០/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាមានិតចិន

១១/ ឯកអគ្គរដ្ឋទូតនៃសហព័ន្ធរុស្ស៊ី

១២/ អនុប្រធានគណបក្សយុត្តិធម៌ និងអភិវឌ្ឍន៍ (AK Parti) និងជាប្រធានទទួលបន្ទុកកិច្ចការបរទេសតួកគីយ៉េ និង

១៣/អនុប្រធានសម្ព័ន្ធសភាកូរ៉េស្តីពី កុមារ ប្រជាជន និងបរិស្ថាន (CPE) នៃរដ្ឋសភាសាធារណរដ្ឋកូរ៉េ។

▪ អញ្ជើញបំពេញការងារនៅក្រៅប្រទេស ចំនួន៤លើក រួមមាន៖

- អញ្ជើញដឹកនាំគណៈប្រតិភូសភានៃព្រះរាជាណាចក្រកម្ពុជា ចូលរួមមហាសន្និបាតលើកទី៤៩ នៃសភាប្រើភាសាបារាំង (APF-49th) ក្រោមមូលបទស្តីពី " បញ្ញាសិប្បនិម្មិត និងសភានិយម " នៅទីក្រុងមុងរ៉េអាល់ ប្រទេសកាណាដា។
- អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់នៃសភាកម្ពុជា ចូលរួមមហាសន្និបាតសហភាពអន្តរសភា (IPU) លើកទី១៤៩ និងកិច្ចប្រជុំពាក់ព័ន្ធ ក្រោមមូលបទ " ការប្រើប្រាស់

វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ សម្រាប់អនាគតប្រកបដោយសន្តិភាព និងចីរភាពកាន់តែប្រសើរ " នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។

- អញ្ជើញចូលរួមអមដំណើរគណៈប្រតិភូជាន់ខ្ពស់កម្ពុជា ដឹកនាំដោយ **សម្តេចតេជោ ប្រធានព្រឹទ្ធសភា** អញ្ជើញចូលរួមវេទិកាចំណេះដឹងពិភពលោកលើកទី២៥ ក្រោមប្រធានបទ " ដំណើរឆ្ពោះទៅរកសហត្ថិភាព " និងកម្មវិធីពាក់ព័ន្ធ នៅសាធារណរដ្ឋកូរ៉េ និង
- អញ្ជើញចូលរួមអមដំណើរ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** អញ្ជើញបំពេញទស្សនកិច្ចផ្លូវការ នៅព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត រដ្ឋកាតា សាធារណរដ្ឋតួកគីយ៉េ និងប្រទេសអេមីរ៉ាតអារ៉ាប់រួម។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ថន្ឋារ៉ា អនុប្រធានទី២ព្រឹទ្ធសភា** បាន៖

- អញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** ដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា បំពេញទស្សនកិច្ចមិត្តភាពនិងផ្លូវការ នៅសាធារណរដ្ឋប្រជាមានិតចិន ចាប់ពីថ្ងៃទី២ ដល់ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៤។
- អញ្ជើញជួបសំណេះសំណាល និងជូនពរ **លោកជំទាវបណ្ឌិត ដេវីយ៉ានី អ៊ុតាំ ខូប្រាហ្គេត** (Devyani Uttam Khobragade) ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥណ្ឌា ប្រចាំព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសដែលលោកជំទាវឯកអគ្គរដ្ឋទូត បញ្ចប់អាណត្តិបេសកកម្មការទូត នៅកម្ពុជា នៅMaline Apartment, Penthouse។

❖ **សមាជិក សមាជិកាព្រឹទ្ធសភា បាន៖**

- អញ្ជើញចូលរួមវេទិកា ទស្សនកិច្ច និងកិច្ចប្រជុំអន្តរជាតិនានា ចំនួន២៥លើក រួមមាន៖
  - ១/ កិច្ចប្រជុំតំបន់អាស៊ី-ប៉ាស៊ីហ្វិក សភាប្រើភាសាបារាំង (Assemblée Parlementaire de la Francophonie) តាមរយៈប្រព័ន្ធនិម្មិត
  - ២/ កិច្ចប្រជុំសភាក្នុងឱកាសនៃទិវាទឹកពិភពលោកលើកទី១០ នៅសាធារណរដ្ឋឥណ្ឌូណេស៊ី
  - ៣/ កិច្ចប្រជុំការងារខ្លឹមសារ និងឯកសារសម្រាប់សម័យប្រជុំពេញអង្គ IPTP លើកទី១១ ជាមួយអនុគណៈកម្មការខ្លឹមសារ និងឯកសារនៃគណៈកម្មការរៀបចំមហាសន្និបាត ICAPP លើកទី១២
  - ៤/ កិច្ចប្រជុំថ្នាក់តំបន់ស្តីពី ជំងឺរបេង ក្រោមប្រធានបទ " លើសពីកិច្ចប្រជុំកម្រិតខ្ពស់របស់អង្គការសហប្រជាជាតិ៖ តំបន់តែមួយ ចក្ខុវិស័យរួមគ្នាតែមួយទៅជាសកម្មភាព " នៅខេត្តសៀមរាប
  - ៥/ កិច្ចប្រជុំគណៈកម្មាធិការអេចិន្ត្រៃយ៍ស្តីពី " កិច្ចការសង្គម និងវប្បធម៌នៃសភាតំបន់អាស៊ី (APA) " នៅទីក្រុងម៉ូស្គូ សហព័ន្ធរុស្ស៊ី
  - ៦/ កិច្ចប្រជុំអំពីវឌ្ឍនភាពការងារជាមួយអនុគណៈកម្មការរៀបចំមហាសន្និបាតសន្និសីទអន្តរជាតិនៃបណ្តាគណបក្សនយោបាយនៅអាស៊ី លើកទី១២ (ICAPP-12$^{th}$) និងកិច្ចប្រជុំពាក់ព័ន្ធ

៧/ កិច្ចប្រជុំជាមួយ **ឯកឧត្តម សួស យ៉ារ៉ា** ប្រធានគណៈកម្មការទី៥ រដ្ឋសភា ដើម្បីពិភាក្សាការងារអំពីការរៀបចំកិច្ចប្រជុំអន្តរសភាអាស៊ាន(AIPA) នៅទីក្រុងវៀងចន្ទន៍ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

៨/ កិច្ចប្រជុំត្រៀមលក្ខណៈចូលរួមមហាសន្និបាតអន្តរសភាអាស៊ាន លើកទី៤៥ (ASEAN Inter-Parliamentary Assembly-AIPA 45th) ដែលនឹងប្រព្រឹត្តទៅនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

៩/ កិច្ចប្រជុំដើម្បីត្រៀមលក្ខណៈចូលរួមកិច្ចប្រជុំរវាងថ្នាក់ដឹកនាំអាយប៉ា លើកទី៤៥ (AIPA-45th)

១០/ កិច្ចប្រជុំទ្វេភាគីជាមួយ **ឯកឧត្តម ខាំបៃ ដាំឡាត់** អនុប្រធានរដ្ឋសភានៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងជាប្រធានសមាគមមិត្តភាពឡាវ-កម្ពុជា

១១/ កិច្ចប្រជុំគណៈកម្មាធិការអេចិន្ត្រៃយ៍នៃបណ្តាញហ្វ្រង់កូហ្វូនសីលធម៌ និងក្រមសីលធម៌សមាជិកសភា តាមប្រព័ន្ធនិម្មិត

១២/កិច្ចប្រជុំបូកសរុបលទ្ធផលនៃការអនុវត្តកិច្ចសហប្រតិបត្តិការរយៈពេល២ឆ្នាំ (ឆ្នាំ២០២២-២០២៤) រវាងសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ខេត្តព្រៃវែង និងសមាគមសហព័ន្ធនារីខេត្តដុងថាប់នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

១៣/ កិច្ចប្រជុំក្រុមមិត្តភាពព្រឹទ្ធសភាកម្ពុជា ជាមួយក្រុមប្រឹក្សាសហព័ន្ធនៃសភាសហព័ន្ធរុស្ស៊ី

១៤/ ពិធីបើកសម័យប្រជុំពេញអង្គ IPTP លើកទី១១ ឆ្នាំ២០២៤

១៥/ មហាសន្និបាតលើកទី៤៩ នៃសភាប្រើភាសាបារាំង(APF) នៅទីក្រុងម៉ុងរ៉េអាល់ ប្រទេសកាណាដា

១៦/ មហាសន្និបាតសន្និសីទអន្តរជាតិ ICAPP លើកទី១២ និងកិច្ចប្រជុំពាក់ព័ន្ធលើកទី២

១៧/ មហាសន្និបាតសហភាពអន្តរសភាលើកទី១៤៩ (IPU-149th) និងកិច្ចប្រជុំពាក់ព័ន្ធនៅទីក្រុងហ្សឺណែវ ប្រទេសស្វីស

១៨/ មហាសន្និបាតអាយប៉ាលើកទី៤៥ (AIPA-45th) និងព័ត៌មានបឋមមួយចំនួនទាក់ទងនឹងការរៀបចំអាយប៉ាលើកទី៤៦ និងលើកទី៤៧ ព្រមទាំងក្រុមប្រឹក្សាពិគ្រោះយោបល់ស្តីពី គ្រឿងញៀន(AIPA-CODD) លើកទី៨ សម័យប្រជុំពេញអង្គលើកទី១ ប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ **ឯកឧត្តម សៃស៊ុមផន កុមវិហាន** (Saysomphone Phomvihane) ប្រធានរដ្ឋសភាឡាវ និងជាប្រធានអាយប៉ា នៅទីក្រុងវៀងចន្ទន៍ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

១៩/ វេទិកា ក្រោមមូលបទ "ភាពជាដៃគូតំបន់ដើម្បីការអភិវឌ្ឍរួម (Regional Partnership for Common Development)" នៅទីក្រុង Huangshan ខេត្ត Anhui នៃសាធារណរដ្ឋប្រជាមានិតចិន

២០/ វេទិកា " ស្ត្រីសហគ្រិន និងសេដ្ឋកិច្ចបៃតង " នៅទីក្រុងហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម

២១/ វេទិកាសមាជិកសភាអាស៊ី-ប៉ាស៊ីហ្វិក លើកទី៨ ស្តីពី សុខភាពសកល (APPFGH) ក្រោមប្រធានបទ " ធនធានមនុស្សសុខាភិបាល " នៅទីក្រុង Port Vila សាធារណរដ្ឋវ៉ានូទូ

២២/ សិក្ខាសាលាអន្តរជាតិស្តីពី បញ្ញាសិប្បនិម្មិត(AI) នៅទីក្រុងម៉ានីល សាធារណរដ្ឋហ្វីលីពីន

២៣/ ទស្សនកិច្ចរបស់គណៈប្រតិភូសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម

២៤/ ទស្សនកិច្ចនៅក្រុមហ៊ុន Cropmate Fertilizer Sdn.Bhd ដែលជាក្រុមហ៊ុនផលិតជីសរីរាង្គពាក់កណ្តាលសរីរាង្គ និងជីគីមី មានទីតាំងនៅទីក្រុងកំពង់ផែ Port Klang នៃប្រទេសម៉ាឡេស៊ី

២៥/ សន្និសីទអន្តរជាតិ ស្តីពី ការបំលាស់ទីរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសហ្វ្រង់កូហ្វូន (La mobilité citoyenne francophone pour la création, l'innovation et l'entrepreneuriat) ដែលបានរៀបចំដោយសភាប្រើភាសាបារាំង (APF) សហការជាមួយទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍(Agence française de développement AFD) ដើម្បីប្រមូលយោបល់ និងអនុសាសន៍ ជូនប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល ដែលចូលរួមកិច្ចប្រជុំកំពូលអង្គការអន្តរជាតិប្រើភាសាបារាំង លើកទី១៩ នៅក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គម ទីក្រុងប៉ារីស នៃសាធារណរដ្ឋបារាំង។

- អញ្ជើញជួបសវនាការ ពិភាក្សាការងារ និងសម្តែងការគួរសមជាមួយភ្ញៀវជាតិ និងអន្តរជាតិនានា ចំនួន៣៤លើក រួមមាន៖

១/ **លោក គឹមយាត ដារ៉ារិទ្ធ** នាយកប្រតិបត្តិមជ្ឈមណ្ឌលសភាអាស៊ី (PCAsia)

២/ **លោក ដាមៀរ មូសែវ** (Mr. Damir Musaev) នាយកប្រតិបត្តិក្រុមហ៊ុនផារ៉ាហ្គន

៣/ អ្នកវិនិយោគទុនជនជាតិអាមេរិក ចំនួន៣នាក់

៤/ **លោកស្រី Aleksandra Zittle** ប្រធានផ្នែកនយោបាយ-សេដ្ឋកិច្ចនៃស្ថានទូតសហរដ្ឋអាមេរិក

៥/ **ឯកឧត្តម ចាង ឈីងលី** អនុប្រធានសភាក្រុមប្រឹក្សានយោបាយប្រជាជនចិនទី១៣ និងជាប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមនៃសភាប្រឹក្សានយោបាយប្រជាជនចិន នៃសាធារណរដ្ឋប្រជាមានិតចិន

៦/ **លោក Ueno Atsushi** ឯកអគ្គរដ្ឋទូតជប៉ុន

៧/ **លោក Kim Jung-Nam** ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ

៨/ **លោកជំទាវ Ülkü Kocaefe** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋតួកគីយ៉េ ចំនួន២លើក

៩/ **ឯកឧត្តមបណ្ឌិត Santo Darmosumarto** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥណ្ឌូណេស៊ី

១០/ **លោក Peter Beynon** ប្រធានក្រុមហ៊ុនJardines

១១/ **Mr. Pablo Kang**, Chargé d'affaires of Australia with Professor Bec Strating, International Relations Department

១២/ **កញ្ញា Rachel Brown** អ្នកស្រាវជ្រាវជនជាតិអាម៉េរិក

១៣/**លោកជំទាវ មីលេណា ខារីដាដ ហ្សាល់ឌីវ៉ា ភីជ្រា** (Milena Caridad Zaldivar Piedra) ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋគុយបា

១៤/ **លោក អាត់ស៊ូស៊ី យ៉ូណេហ្សាវ៉ា** (Atsushi Yonezawa) ប្រធានកុងស៊ុលជប៉ុន ប្រចាំខេត្តសៀមរាប

១៥/ **លោក ណាកាសិ កិនស៊ូកិ** (Nagase Kensuke) អគ្គទីប្រឹក្សាស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា ចំនួន២លើក

១៦/ **ឯកឧត្តម ស្តេហ្វានុស បេន លីអូ** (Stefanus B.A.N.Liow) ប្រធានទីភ្នាក់ងារកិច្ចការនីតិប្បញ្ញត្តិប្រចាំតំបន់នៃសភាតំណាងតំបន់នៃសាធារណរដ្ឋឥណ្ឌូណេស៊ី

១៧/ គណៈប្រតិភូវិនិយោគជនជាតិជប៉ុនអំពីការវិនិយោគ និងការបណ្តាក់ទុនលើវិស័យកសិកម្ម និងកសិឧស្សាហកម្ម នៅតំបន់អភិវឌ្ឍន៍កសិទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ ខេត្តកំពង់ស្ពឺ

១៨/ **លោក អ៊ីហ្គ័រ ខារ៉ាវ៉ា** (Igor Karavaev) ភារធារីស្តីទីស្ថានទូតរុស្ស៊ី ប្រចាំព្រះរាជា-ណាចក្រកម្ពុជា

១៩/ **លោកស្រី រ៉ាស្សាហ្វាយ ជ្រាហ្សី មីរ៉ាណា** (Razafindrazay Mirana) អគ្គលេខាធិការព្រឹទ្ធសភាម៉ាដាហ្គាស្កា

២០/ **ឯកឧត្តម អ៊ីហ្គោរ៍ ទ្រីសម៉ាន់** (Igor Driesmans) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃស្ថានបេសកកម្មសហភាពអឺរ៉ុប(EU) ចំនួន២លើក

២១/**លោកស្រី កូហ្គា អាស៊ូកា** (Koga Asuka) លេខាទី៣នៃស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា

២២/**លោក Andrew McDowell** អគ្គនាយកនៃធនាគារវិនិយោគអឺរ៉ុប ដែលមានទីតាំងនៅបូរីក្សេត្រលុចសំបួ

២៣/**លោក Ivan Kabacoff** អ្នករៀបចំកម្មវិធីតុមូលស្តីពី ភាពរំកិលនៃអនាគតៈ ចរាចរក្នុងកន្លែងនិយាយភាសាបារាំងរបស់សិស្ស បុគ្គលហាត់ការកូនជាង និងបុគ្គលស្ម័គ្រចិត្តវ័យក្មេង នៅក្នុងសន្និសីទរៀបចំដោយ APF តាមរយៈ Video Conference

២៤/ ក្រុមប្រឹក្សាសហព័ន្ធនៃសភាសហព័ន្ធរុស្ស៊ី

២៥/ **លោកស្រី Nino Bujiashvili** ប្រធាននាយកដ្ឋានជំនាញកិច្ចការអន្តរជាតិ និងជាម្ចាស់ពានរង្វាន់ Geoffrey-Dieudonné នៃសភាប្រើភាសាបារាំង (APF) ប្រចាំឆ្នាំ២០២៣

២៦/ **លោក ផាក ឌុកហ៊ីម** (Park Duk Hyum) អនុប្រធានសម្ព័ន្ធសភាកូរ៉េ

២៧/ **លោក យ៉ុង ចាងមីន** ( Byong Jang Min ) តំណាងមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ

២៨/ **លោកជំទាវ** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋហ្វីលីពីន ប្រចាំព្រះរាជាណាចក្រកម្ពុជា

២៩/ **លោកស្រីបណ្ឌិត មីលីង ហ្សាវ** ( Meiling Zhao ) ប្រធានសហគមន៍ការពារសិទ្ធិ និងអភិវឌ្ឍន៍ស្ត្រី នៅតំបន់អាស៊ី និងអាហ្វ្រិកនៃសាធារណរដ្ឋប្រជាមានិតចិន

៣០/ ក្រុមសាស្ត្រាចារ្យកូរ៉េ និង

៣១/ **លោកស្រី រួអេដា អិល ហាច** ( Roueida El Hage ) តំណាងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា( OHCHR )។

- អញ្ជើញចូលរួមពិសាអាហារការងារជាមួយភ្ញៀវជាតិ និងអន្តរជាតិ ចំនួន១៤លើក និង
- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរទិវាបុណ្យជាតិបណ្ដាប្រទេសនានា និងពិធីផ្សេងៗ ចំនួន២៤លើក។

- សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បាន៖

- អញ្ជើញចូលរួមអមដំណើរ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា បំពេញទស្សនកិច្ចផ្លូវការនៅក្រៅប្រទេស ចំនួន៣លើក រួមមាន៖
  - សាធារណរដ្ឋកូរ៉េ
  - សាធារណរដ្ឋប្រជាមានិតចិន និង
  - ព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត រដ្ឋកាតា សាធារណរដ្ឋតួកគីយ៉េ និងប្រទេសអេមីរ៉ាតអារ៉ាប់រួម។
- អញ្ជើញចូលរួមអម **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** ក្នុងជំនួបសម្ដែងការគួរសម និងពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិនានា ចំនួន ៩១លើក។
- អញ្ជើញចូលរួមអមដំណើរ **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា** ដឹកនាំគណៈប្រតិភូជាន់ខ្ពស់នៃសភាកម្ពុជា ចូលរួមមហាសន្និបាតសហភាពអន្តរសភា លើកទី១៤៩ ( IPU- 149$^{th}$ ) និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។
- អញ្ជើញចូលរួមកិច្ចប្រជុំសមាគមអគ្គលេខាធិការសភាក្នុងក្របខ័ណ្ឌនៃសហភាពអន្តរសភា ( IPU ) នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស និង
- អនុញ្ញាតឱ្យភ្ញៀវអន្តរជាតិ ចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារ ចំនួន៦លើក។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា បាន៖

- អញ្ជើញចូលរួមក្នុងជំនួបសម្ដែងការគួរសម និងពិភាក្សាការងាររវាងថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា ជាមួយភ្ញៀវអន្តរជាតិនានា និងកម្មវិធីផ្សេងៗ ចំនួន៦លើក និង

- អញ្ជើញជាអធិបតីក្នុងពិធីប្រគល់ និងទទួលអំណោយជាកុំព្យូទ័រ ចំនួន៦០គ្រឿង ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជូនអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តំណាងដោយ **ឯកឧត្តម ទូច យ៉ារ៉ាន់ឌី** អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

❖ **ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយក្រុមវិស្វករជនជាតិចិន ដឹកនាំដោយ **លោក Zhang Junping** ប្រធានក្រុមវិស្វករជនជាតិចិន ដែលទទួលបន្ទុកសាងសង់អគារការិយាល័យធ្វើការរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានរដ្ឋសភា បានសហការជាមួយព្រឹទ្ធសភាម៉ាដាហ្គាស្កា និងសមាគមបេសកកម្មសិក្សាអាស៊ី-អាហ្វ្រិក រៀបចំពិធីធ្វើបទបង្ហាញស្តីពី " ការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភាម៉ាដាហ្គាស្កា " ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រដ្ឋសភា ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា និង**លោកជំទាវ រ៉ាស្សាហ្វីន ដ្រាហ្សេ មីរ៉ាណា** (Razafindrazay Mirana) អគ្គលេខាធិការព្រឹទ្ធសភាម៉ាដាហ្គាស្កា នៅសាលខាងជើង វិមានព្រឹទ្ធសភា និង
- បានសហការ និងទាក់ទងជាមួយស្ថានទូតសិង្ហបុរី ស្ថានទូតចិន ស្ថានទូតម៉ាឡេស៊ី ស្ថានទូតប្រ៊ុយណេដារូហ្សាឡាម ស្ថានទូតឥណ្ឌា ស្ថានទូតថៃ ស្ថានទូតវៀតណាម ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ទីស្តីការគណៈរដ្ឋមន្ត្រី អង្គការសេវាកម្មអ្នកជំនាញការជាន់ខ្ពស់អាល្លឺម៉ង់(SES) អង្គការមូលនិធិអាស៊ី មជ្ឈមណ្ឌលសភាអាស៊ី (PCAsia) មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់កម្ពុជា មជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន(CALRC) មជ្ឈមណ្ឌលកម្ពុជា៤.0 បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា(CADT) វិទ្យាស្ថានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ វិទ្យាស្ថានប្រសិទ្ធ វិទ្យាស្ថានសាន់វ៉ាយស៍ វិទ្យាស្ថានSalaCyber វិទ្យុមិត្តភាពកម្ពុជា-ចិន ក្រុមហ៊ុនកូហាបណ្ណសារដ្ឋានជាតិ បណ្ណាល័យ និងក្រសួង ស្ថាប័ននានា ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការស្នើសុំអាហារូបករណ៍ ការរៀបចំវគ្គបណ្តុះបណ្តាល ជំនួយ ព្រមទាំងការរៀបចំពិធីផ្សេងៗ។

## ៥-មុខងារអភិវឌ្ឍន៍ស្ថាប័ន

### ៥.១-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ

- បានរៀបចំរបាយការណ៍ប្រជុំការពារគម្រោងថវិកាឆ្នាំ២០២៥ និងគម្រោងបែងចែកកញ្ចប់ថវិកាព្រឹទ្ធសភាឆ្នាំ២០២៥ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា (នីតិកាលទី៥) ពិនិត្យ និងសម្រេច។
- បានប្រជុំការពារគម្រោងថវិកាឆ្នាំ២០២៥ របស់ព្រឹទ្ធសភា កម្រិតបច្ចេកទេស និងកម្រិតថ្នាក់ដឹកនាំព្រឹទ្ធសភា ជាមួយថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- បានរៀបចំរបាយការណ៍ទូទាត់ថវិការបស់ព្រឹទ្ធសភាប្រចាំឆ្នាំ២០២៣ និងឧបសម្ព័ន្ធ និងរបាយការណ៍ទូទាត់ថវិកាប្រចាំនីតិកាលទី៤ (ឆ្នាំ២០១៨-២០២៣) ដើម្បីរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥។

- បានបោះផ្សាយអាណត្តិ និងចុះប្រព័ន្ធ FMIS ជំពូក ៦០ ៦១ ៦២ និង៦៤ សម្រាប់ត្រីមាសទី១ ទី២ ទី៣ និងទី៤ ឆ្នាំ២០២៤។
- បានរៀបចំបូកសរុបផែនការតម្រូវការសម្ភារ និងថវិកាប្រចាំឆ្នាំ២០២៥ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានបែងចែកតារាងប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ ប្រចាំឆ្នាំ២០២៤ ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានបើកប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារបន្ថែម ប្រាក់ឧបត្ថម្ភពិនិត្យ និងព្យាបាលជំងឺ ប្រាក់ឧបត្ថម្ភធ្វើដំណើរ និងសេវាទំនាក់ទំនងប្រចាំខែនីមួយៗ ក្នុងឆ្នាំ២០២៤ ប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ប្រាក់ឧបត្ថម្ភបុណ្យភ្ជុំបិណ្ឌ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា មន្ត្រីនគរបាលសន្តិសុខ ជំនួយការផ្ទាល់ អ្នកបើកបររថយន្ត និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមរយៈប្រព័ន្ធធនាគារ។
- បានបង្វែរប្រាក់ភាគទានជូនអង្គភាពបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែនីមួយៗ ក្នុងឆ្នាំ២០២៤។
- បានទិញរថយន្ត Ford ចំនួន១១គ្រឿង រថយន្ត Ford ១៥កៅអី ចំនួន២គ្រឿង និងរថយន្ត Land Cruiser ចំនួន២គ្រឿង។
- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៥៣៨សំណើ ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗ ចំនួន១,៦០៧សំណើ។
- បានដោះស្រាយសំណើផ្សេងៗ និងផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខាសាលា កម្មវិធីផ្សេងៗ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៥៥០សំណើ។
- បានថតចម្លងឯកសារ ចំនួន៤២,៤៣៩ច្បាប់ ចងក្រងធ្វើជាសៀវភៅ ចំនួន២៦១ក្បាល ប្រើប្រាស់ក្រដាសអស់ ចំនួន៤៧៧,២៣៨សន្លឹក។
- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តទាំង៨ ភូមិភាគ ចំនួន៨៨៥លើក ស្មើនឹង១,៩៥៩នាក់។
- បានរៀបចំ បោសសម្អាត តុបតែងលម្អសាល តាំងលម្អផ្កាមុខអគារក្រហម និងសាលជំនួបភ្ញៀវ ព្រមទាំងផ្តល់សេវាបម្រើភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន២៥៩លើក ស្មើនឹង៧,៩៣៥នាក់។
- បានទទួលលិខិតចូល ចំនួន៦,៣០៨ច្បាប់ និងបញ្ជូនលិខិតចេញទៅក្រសួង ស្ថាប័នពាក់ព័ន្ធនានា ចំនួន២,៨៣៦ច្បាប់។

- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១៨៣ច្បាប់ ស្មើនឹង៨២០នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភា ចំនួន៥២ច្បាប់។
- បានចុះសួរសុខទុក្ខមន្ត្រីរាជការមានជំងឺ លំហែមាតុភាព និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ចំនួន៧១នាក់។
- បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ មែកឈើ និងផ្កានានា ចំនួន១៥២លើក និងបានដាំស្មៅ តាំងលម្អផ្កាស្បៃរឿង ផ្កាចម្រុះពណ៌ និងរុក្ខជាតិលម្អនានា ព្រមទាំងបានសម្អាតបរិស្ថាន អនាម័យតាមអគារធ្វើការ និងក្នុងបរិវេណព្រឹទ្ធសភាជាប្រចាំ។
- បានយកចិត្តទុកដាក់ការងារអនាម័យ បរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ផ្លូវចំណតរថយន្ត ការងារសន្តិសុខ និងសណ្តាប់ធ្នាប់ ដើម្បីធានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង។
- បានធ្វើបញ្ជីស្ថិតិមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆ្នាំ២០២៤ រួមមានៈ
  - មន្ត្រីរាជការក្របខ័ណ្ឌ ចំនួន៧១៧នាក់ (ប្រុស៤២៥នាក់ ស្រី២៩២នាក់)។
  - បុគ្គលិកជាប់កិច្ចសន្យា ចំនួន៨៤នាក់ (ប្រុស៤៩នាក់ ស្រី៣៥នាក់)។
  - មន្ត្រីរាជការមានមុខតំណែងគ្រប់គ្រង ចំនួន៤៩៤នាក់ (ប្រុស៣០៧នាក់ ស្រី១៨៧នាក់)។
  - មន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ចំនួន១១នាក់ និង
  - មន្ត្រីរាជការព្យួរនៅក្រៅក្របខ័ណ្ឌដើម ចំនួន៣នាក់។
- បានធ្វើសេចក្តីសម្រេច ចំនួន៣៥ច្បាប់ និងលិខិតបង្គាប់ការ ចំនួន២១ច្បាប់។
- បានផលិតប័ណ្ណអភ័យឯកសិទ្ធិជូនសមាជិក សមាជិកាព្រឹទ្ធសភា នីតិកាលទី៥ ចំនួន៦២ប័ណ្ណ។
- បានធ្វើតារាងបញ្ជាក់ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ លិខិតផ្តត់ផ្តង់ និងវិញ្ញាបនបត្របញ្ជាក់រយៈពេលបំពេញការងាររដ្ឋ ចំនួន៥៧ច្បាប់។
- បានធ្វើបញ្ជីរាយនាមមន្ត្រីរាជការស្នើសុំប្រាក់វិភាជន៍គ្រួសារ (ប្រពន្ធ-កូន) ប្រចាំឆ្នាំ២០២៤ (មន្ត្រីរាជការស្នើសុំបញ្ចូលប្រាក់ឧបត្ថម្ភសម្រាប់ប្រពន្ធ ចំនួន៥នាក់ និងកូន ចំនួន១៦នាក់)។
- បានរៀបចំការប្រឡងជ្រើសរើសក្រុមមន្ត្រីព័ត៌មាននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានសហការជាមួយបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រៀបចំធ្វើប័ណ្ណសមាជិក (ប.ស.ស) ជូនអ្នកក្នុងបន្ទុក (សហព័ទ្ធ និងកូន) របស់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន២០៨ប័ណ្ណ។
- បានបញ្ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១៣៨នាក់ ចូលរួមវគ្គបណ្តុះបណ្តាលនៅក្នុងស្ថាប័នព្រឹទ្ធសភា ចំនួន១២វគ្គ។
- បានបញ្ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១១៤នាក់ ចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា នៅក្រៅស្ថាប័នព្រឹទ្ធសភា ចំនួន២១វគ្គ។
- បានបញ្ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១២នាក់ ចូលរួមវគ្គបណ្តុះបណ្តាល ចំនួន២វគ្គ នៅសាធារណរដ្ឋប្រជាមានិតចិន។

- បានធ្វើផែនការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សរយៈពេល៦ឆ្នាំ (ឆ្នាំ២០២៤-២០៣០) នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានរៀបចំផែនការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សឆ្នាំ២០២៥។
- បានរៀបចំធ្វើបច្ចុប្បន្នភាពសារពើភ័ណ្ឌជំនាញ និងតម្រូវការបណ្តុះបណ្តាលរបស់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បន្តយកចិត្តទុកដាក់ចូលរួមក្នុងដំណើរការកសាងអគារថ្មីព្រឹទ្ធសភា។
- ការងារសាងសង់សំណង់ថ្មីៗ ជួសជុលកែលម្អអគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ រួមមានៈ
  - បានជួសជុល កែលម្អៈ
    ១/ អគារក្រហមព្រឹទ្ធសភា
    ២/ អគារការិយាល័យសម្រាប់បំពេញការងារជូននាយកដ្ឋានរដ្ឋបាល បណ្ណាល័យ និងសមាគមសង្គហៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
    ៣/ អតីតអគារស្នាក់នៅរបស់អង្គភាពសន្តិសុខប្រគល់ជូនអង្គភាពការពារព្រឹទ្ធសភា
    ៤/ ពង្រីកកន្លែងស្នាក់នៅរបស់មន្ត្រីសេវាកម្ម
    ៥/ ក្រាលការ៉ូឈើជាន់ក្រោម នៅអគារ D.E.F
    ៦/ ជួសជុល និងប្តូរការ៉ូបាត នៅនាយកដ្ឋានភូមិភាគ និងសមូហភាពដែនដី បន្ទប់ទឹកនៅគណៈកម្មការទី៣ និងទី៦ព្រឹទ្ធសភា
    ៧/ ជួសជុលកែលម្អ ប្តូរទ្វារបង្អួច និងបំពាក់កែងអូតូ នៅអគារខុទ្ទកាល័យឯកឧត្តមអគ្គលេខា-ធិការព្រឹទ្ធសភា គណៈកម្មការទី២ និងទី៣ព្រឹទ្ធសភា និង
    ៨/ បិទក្រដាសជញ្ជាំងនៅការិយាល័យឯកឧត្តមអគ្គលេខាធិការរងព្រឹទ្ធសភា។
  - បានបំពាក់ផ្ទាំងគំនូរ និងព្រះឆាយាល័ក្ខណ៍ **ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា នៅបន្ទប់ការិយាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា បន្ទប់ការិយាល័យឯកឧត្តមអគ្គលេខា-ធិការព្រឹទ្ធសភា និងអគារខុទ្ទកាល័យឯកឧត្តមអគ្គលេខាធិការរងព្រឹទ្ធសភា។
  - បានធ្វើស្លាកឈ្មោះបន្ទប់ នៅតាមអគារថ្នាក់ដឹកនាំព្រឹទ្ធសភា និងអង្គភាពនានា ចំនួន ៣៤បន្ទប់។
  - បានលាបថ្នាំដងទង់ជាតិនៅខាងមុខអគារក្រហមព្រឹទ្ធសភា និងលាបថ្នាំរបងថ្មីនៅបរិវេណព្រឹទ្ធសភា។
  - បានជួសជុល ចាក់បេតុងស៊ីម៉ង់ត៍ ក្រាល-អ៊ុតកៅស៊ូ នៅមុខអគារការិយាល័យឯកឧត្តមអគ្គលេខាធិការរងព្រឹទ្ធសភា សួនច្បារខាងមុខអគារក្រហមព្រឹទ្ធសភា។
  - បានបង្រួមសួន និងពង្រីកផ្លូវ នៅមុខអគារក្រហមព្រឹទ្ធសភា ។
  - បានជួសជុលផ្លូវបាក់ស្រុត និងពង្រីកកងចន្ទល់ដើមឈើនៅក្នុងបរិវេណព្រឹទ្ធសភា។
  - បានគូសគំនូសចរាចរណ៍នៅក្នុងបរិវេណព្រឹទ្ធសភា
  - បានសាងសង់បន្ទប់ស្នាក់នៅរបស់នគរបាលនៅច្រកចេញ-ចូលព្រឹទ្ធសភា (P2) និងជួសជុលដំបូលស័ង្កសី នៅប៉ុស្តិ៍យាម P4 និង

- បានជួសជុល និងធ្វើគម្របលូថ្មី ស្តារប្រព័ន្ធលូ បាញ់លាងសម្អាតតាមដងផ្លូវក្នុងបរិវេណព្រឹទ្ធសភា។

- បានជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធអគារ បណ្តាញទឹក បណ្តាញអគ្គិសនី ត្រួតពិនិត្យជណ្តើរយន្ត កំចាត់សត្វកណ្តៀរ រៀបចំ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារិម ប្រមូលសម្ភារខូច បិទលេខកូដសម្ភារសារពើភ័ណ្ឌ ប្រគល់ និងបំពាក់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតក្នុងបរិវេណព្រឹទ្ធសភា ចំនួន៣,០៦៨គ្រឿង/លើក។
- បានធ្វើសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ នៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានផ្តល់សេវាធ្វើ និងផ្លាស់ប្តូរស្លាកលេខព្រឹទ្ធសភា-រដ្ឋ ០០១ ខ្ចី-វែង នីតិកាលទី៥ ជូនថ្នាក់ដឹកនាំសមាជិក សមាជិកាព្រឹទ្ធសភា ចំនួន១០០គ្រឿង។
- បានធ្វើរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី១ និងលើកទី២ នីតិកាលទី៥។
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែនីមួយៗ និងប្រចាំឆ្នាំ២០២៤ ទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា។
- បានធ្វើបទបង្ហាញ និងរបាយការណ៍ស្តីពី ការប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែនីមួយៗ ក្នុងឆ្នាំ២០២៤ និង
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែនីមួយៗ និងប្រចាំឆ្នាំ២០២៤ ព្រមទាំងបានផ្សព្វផ្សាយលើគេហទំព័រព្រឹទ្ធសភា និងផ្ញើជូនក្រសួង ស្ថាប័នពាក់ព័ន្ធនានា។

**៥.២-ការងារសេវាច្បាប់៖**

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស សារាចរណែនាំ របាយការណ៍ សេចក្តីជូនដំណឹង និងលិខិតផ្សេងៗ ចំនួន១៥៣ច្បាប់ ពីក្រសួង និងស្ថាប័ននានា។
- បានទទួលសេចក្តីព្រាងច្បាប់ ចំនួន៦ច្បាប់ ពីទីស្តីការគណៈរដ្ឋមន្ត្រី និងចំនួន៦ច្បាប់ ពីរដ្ឋសភា ព្រមទាំងបានថ្វាយ និងចែកគ្រប់សមាជិក សមាជិកាព្រឹទ្ធសភា។
- បានធ្វើឯកសារទស្សនទានពាក់ព័ន្ធនឹងមុខងារតំណាងរបស់ព្រឹទ្ធសភា នីតិកាលទី៤ និងទិសដៅការងារសម្រាប់នីតិកាលទី៥។
- បានធ្វើជំនួយស្មារតីក្នុងកិច្ចដំណើរការនៃការបើកសម័យប្រជុំដំបូងព្រឹទ្ធសភា សម័យប្រជុំលើកទី១ និងលើកទី២ព្រឹទ្ធសភា កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ សម្រាប់ថ្នាក់ដឹកនាំព្រឹទ្ធសភា ចំនួន២៤លើក ។
- បានធ្វើជំនួយស្មារតីជូនលេខាធិការសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៥ ចំនួន៨លើក។

- បានធ្វើកំណត់ហេតុពិស្តារ និងកំណត់ហេតុសង្ខេបនៃកិច្ចប្រជុំដំបូងព្រឹទ្ធសភា កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា សម័យប្រជុំលើកទី១ និងលើកទី២ព្រឹទ្ធសភា ប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ចំនួន៣៤លើក។
- បានធ្វើកំណត់ហេតុពិស្តារនៃកិច្ចប្រជុំអន្តរគណៈកម្មការស្តីពី សេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ចំនួន១លើក។
- បានប្រមូលផ្តុំចងក្រងឯកសារ លិខិតបទដ្ឋាននានា និងបោះពុម្ពសៀវភៅស្តីពី៖
  - សមិទ្ធផលការងារព្រឹទ្ធសភា នីតិកាលទី៤ (ឆ្នាំ២០១៨-២០២៤)។
  - បញ្ជីឈ្មោះច្បាប់ ដែលព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ (ចាប់ពីនីតិកាលទី១ ដល់នីតិកាលទី៤) និង
  - កម្រងកំណត់ហេតុពិស្តារ និងសង្ខេបនៃកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា និងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា (ចាប់ពីនីតិកាលទី១ ដល់នីតិកាលទី២ ឆ្នាំ១៩៩៩-២០១១)។
- បានធ្វើបច្ចុប្បន្នភាពសៀវភៅព័ត៌មានស្ថិតិ និងទិន្នន័យ ជូនថ្នាក់ដឹកនាំនាយកដ្ឋាន និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨។
- បានរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨។
- បានជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន និងសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។
- បានធ្វើបច្ចុប្បន្នភាពបញ្ជីសេចក្តីព្រាងច្បាប់ដែលព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់តាមឆ្នាំ និងនីតិកាលនីមួយៗ។
- បានទាក់ទងជាមួយរដ្ឋបាលរាជធានី ខេត្ត ដើម្បីត្រៀមរៀបចំជូនថ្នាក់ដឹកនាំ អញ្ជើញចុះជួបសំណេះសំណាល សួរសុខទុក្ខក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រមូលព័ត៌មានថ្មីៗ ដើម្បីធ្វើបច្ចុប្បន្នភាពក្រុមប្រឹក្សាខណ្ឌ ក្រុង ស្រុក ឃុំ សង្កាត់។
- បានធ្វើសេចក្តីជូនដំណឹងស្តីពី ការប្រកាសទ្រព្យសម្បត្តិ និងបំណុល ជូនបុគ្គលចប់អាណត្តិ ឬលាលែងសម្រាប់នីតិកាលទី៤ និងបុគ្គលបានទទួលការតែងតាំង ក្នុងនីតិកាលទី៥ និងតាមរបប២ឆ្នាំសម្រាប់នីតិកាលទី៥ និងបានផ្សព្វផ្សាយតាមបណ្តាញសង្គម និងគេហទំព័ររបស់ព្រឹទ្ធសភា។
- បានសម្រួលដំណើរការបញ្ជូនឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល តាមរបប២ឆ្នាំ ចប់អាណត្តិ ឬលាលែងពីមុខតំណែង និងទទួលការតែងតាំងថ្មី នៅព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះបុគ្គលជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុល នៅព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានតាមដានដំណើរការវិវឌ្ឍសម័យប្រជុំរបស់រដ្ឋសភា។
- បានផ្តល់សេវារដ្ឋបាល បច្ចេកទេស ព័ត៌មាន ពិធីការ ទំនាក់ទំនងការងារ ជូនគណៈកម្មការទាំង១០ និងក្រុមនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្ម និងកម្មវិធីផ្សេងៗ ចំនួន១,៣៧០លើក។

## ៤.៣-ការងារស្រាវជ្រាវ៖

- បានសិក្សាស្រាវជ្រាវ និងកសាងជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ ចំនួន៦ច្បាប់។
- បានសិក្សាស្រាវជ្រាវ និងកសាងជំនួយស្មារតីលើប្រធានបទនានា ចំនួន១១ប្រធានបទ។
- បានតាមដាន សិក្សាស្រាវជ្រាវ និងចងក្រងឯកសារលើប្រធានបទនានា ចំនួន២២ប្រធានបទ។
- បានសិក្សាស្រាវជ្រាវ និងធ្វើសំយោគឯកសារព័ត៌មាន និងសង្ខេបខ្លឹមសារពាក់ព័ន្ធនឹងវិស័យនានា ចំនួន៨៥អត្ថបទ។
- បានធ្វើបទបង្ហាញអំពីលទ្ធផលនៃការសិក្សាស្រាវជ្រាវលើសេចក្តីព្រាងច្បាប់នានា ជូនគណៈកម្មការព្រឹទ្ធសភានានា។
- បានរៀបចំប្រមូលទិន្នន័យថវិកាមូលនិធិ ថ្នាក់ឃុំ សង្កាត់ រយៈពេល១០ឆ្នាំ ចុងក្រោយ។
- បានចងក្រងទិន្នន័យលិខិតបទដ្ឋានគតិយុត្តតាមវិស័យរបស់គណៈកម្មការនានា។
- បានបំប្លែងឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តតាមវិស័យទៅជាឯកសារឌីជីថល និងធ្វើបច្ចុប្បន្នភាពកម្រងច្បាប់ព្រឹទ្ធសភាក្នុងប្រព័ន្ធមូលទិន្នន័យ។
- បានស្រង់ឯកសារពីក្នុងរាជកិច្ច និងចាត់ថ្នាក់ទៅតាមវិស័យច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត។
- បានបញ្ចូលទិន្នន័យថវិកាចំណូល-ចំណាយក្នុងតារាងប្រតិបត្តិការហិរញ្ញវត្ថុ និងសេដ្ឋកិច្ច (TOFE) ប្រចាំខែនីមួយៗ ក្នុងឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- បានបកប្រែ និងសង្ខេបព័ត៌មានសភាបញ្ចូលក្នុងសម្រង់សង្ខេបព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ចំនួន ២,៥៥៨ព័ត៌មាន។
- បានសិក្សាស្រាវជ្រាវ និងចងក្រងទិន្នន័យព័ត៌មានសភាអន្តរជាតិ ចំនួន៩៩ប្រទេស និង
- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច ប្រចាំសប្តាហ៍ ចំនួន២៨ច្បាប់។

## ៤.៤-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖

- បានរៀបចំចងក្រងឯកសារបើកសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី៥។
- បានសម្របសម្រួលអ្នកសារព័ត៌មាន ចំនួន៦០អង្គភាព ចូលយកព័ត៌មានក្នុងពិធីបើកសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី៥។
- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា ចំនួន១៤៩លើក។
- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងសកម្មភាពការងាររបស់ព្រឹទ្ធសភា និង អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធ Facebook, Instagram, X (Former Twitter), Youtube និងTiktok ចំនួន៨,៩៣៨លើក។
- បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភា ចំនួន១,៨១៨ប្រធានបទ។

- បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុងឆានែលតេឡេក្រាម ព័ត៌មានប្រចាំថ្ងៃ ចំនួន១៤,៦៩២ ប្រធានបទ។
- បានអញ្ជើញអ្នកសារព័ត៌មាននៃទូរទស្សន៍ជាតិកម្ពុជា ចូលយកព័ត៌មាន ក្នុងកិច្ចប្រជុំសំខាន់ៗរបស់ព្រឹទ្ធសភា ជំនួបសម្តែងការគួរសម ពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ និងកម្មវិធីផ្សេងៗ ចំនួន១០១លើក។
- បានតាំងពិព័រណ៍រូបភាពសកម្មភាពរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាគណៈកម្មការទាំង១០ ក្រុមភូមិភាគទាំង៨ និងក្រុមយន្តការនានារបស់ព្រឹទ្ធសភា នៅក្នុងបណ្ណាល័យព្រឹទ្ធសភា និងខ្លោងទ្វារធំព្រឹទ្ធសភា ចំនួន១១០លើក។
- បានផលិត និងផ្សព្វផ្សាយទស្សនាវដ្តីព្រឹទ្ធសភាប្រចាំខែនីមួយៗ ក្នុងឆ្នាំ២០២៤។
- បានរៀបចំផលិត និងបោះពុម្ពៈ
  - សៀវភៅស្តីពី ការអភិវឌ្ឍព្រឹទ្ធសភាក្នុងរយៈពេល២៥ឆ្នាំ (១៩៩៩-២០២៤) ចំនួន ១០០ក្បាល។
  - សៀវភៅទិនានុលេខន៍របស់ព្រឹទ្ធសភា ឆ្នាំ២០២៥ ចំនួន១,៥០០ក្បាល។
  - ប្រតិទិនរបស់ព្រឹទ្ធសភា ឆ្នាំ២០២៥ ចំនួន១,៥០០ក្បាល និង
  - ប័ណ្ណរថយន្តចេញ-ចូល ក្នុងបរិវេណព្រឹទ្ធសភា ឆ្នាំ២០២៥ ចំនួន៣,៤០០សន្លឹក។
- បានផលិតព្រឹត្តិបត្រស្តីពី បច្ចេកវិទ្យាព័ត៌មាន ប្រចាំខែសីហា ដល់ខែធ្នូ ឆ្នាំ២០២៤ ចំនួន៥ច្បាប់។
- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធណេតវើក អ៊ិនធឺណែត ពង្រឹងពង្រីកការផ្គត់ផ្គង់ និងជួសជុលឧបករណ៍ សម្ភារ បរិក្ខារបច្ចេកទេស ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មាន ចំនួន៨១៧គ្រឿង/លើក។
- បានធ្វើបច្ចុប្បន្នភាពគេហទំព័រព្រឹទ្ធសភា នីតិកាលទី៥។
- បានរៀបចំប្រព័ន្ធស្ទូឌីយ៉ូ ប្រព័ន្ធសំឡេង ប្រព័ន្ធមេក្រូហ្វូន ប្រព័ន្ធរូបភាព ប្រព័ន្ធកាមេរ៉ា និងប្រព័ន្ធប្រជុំនិម្មិត ឬប្រព័ន្ធប្រជុំពីចម្ងាយ(Digital) ក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ ព្រមទាំងកិច្ចប្រជុំសំខាន់ៗរបស់ព្រឹទ្ធសភា ចំនួន២៦៨លើក។
- បានរៀបចំកម្មវិធីទទួលពាក្យបណ្តឹងព្រឹទ្ធសភាអេឡិចត្រូនិច (Mobile Application) និងយុទ្ធសាស្ត្រផ្សព្វផ្សាយ។
- បានរៀបចំបំប្លែងកាសែតវីដេអូចាស់ៗរបស់ព្រឹទ្ធសភា ទៅជាប្រភេទវីដេអូឌីជីថល ដើម្បីរក្សាទុកក្នុងប្រព័ន្ធទិន្នន័យ។
- បានទទួលឯកសារ ទស្សនាវដ្តី ព្រឹត្តិបត្រ រាជកិច្ច សៀវភៅច្បាប់ និងសៀវភៅជំនាញផ្សេងៗ ចំនួន១,៦៨៥ក្បាល ព្រមទាំងបានចុះបញ្ជីសៀវភៅ ដាក់លេខកូដសៀវភៅ អ៊ុតក្របសៀវភៅ បោះត្រាបិទប័ណ្ណខ្ចី និងសងសៀវភៅ ចំនួន២,៩៥២ក្បាល។
- បានរៀបចំបញ្ចូលទិន្នន័យឯកសារ និងសៀវភៅក្នុងកម្មវិធីកូហា ចំនួន១,០០១ក្បាល។
- បានផ្សព្វផ្សាយឯកសាររបស់ព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឯកសារច្បាប់ ឯកសារជំនាញផ្សេងៗ និងសៀវភៅជា E-Book តាម www.elibrary.senate.gov.kh ចំនួន៧,៥៦៤ក្បាល ដែលមានសាធារណជនចូលអាន ចំនួន១,០២២នាក់ និង

- បានផ្សព្វផ្សាយឯកសារ និងសៀវភៅដែលមាននៅក្នុងបណ្ណាល័យព្រឹទ្ធសភា ក្នុងផេក TikTok របស់បណ្ណាល័យព្រឹទ្ធសភា (មាន Follower ចំនួន៣៣៣នាក់ និងអ្នក Like ចំនួន៣១,៣០៨នាក់)។

### ៤.៥-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិ៖

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ ជំនួបសម្តែងការគួរសម ពិភាក្សាការងារ និងពិធីផ្សេងៗ ចំនួន៣២៦លើក។
- បានរៀបចំជំនួយស្មារតី សុន្ទរកថា បទអន្តរាគមន៍ និងបកប្រែឯកសារនានា ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ចំនួន៦៩ច្បាប់/លើក។
- បានរៀបចំបែបបទស្នើសុំលិខិតឆ្លងដែនការទូត និងផ្លូវការជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងក្រុមគ្រួសារ ចំនួន១០៩រូប។
- បានផលិត និងផ្សព្វផ្សាយ " ព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិ " ប្រចាំខែនីមួយៗ និងប្រចាំឆ្នាំ២០២៤" ចំនួន៩ច្បាប់។
- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន៤៩ច្បាប់។
- បានចងក្រងឯកសារ បញ្ជីឈ្មោះអង្គការជាតិ និងអង្គការអន្តរជាតិ សេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍រួមរបស់អង្គការសង្គមស៊ីវិល និងក្រសួងនានា និង
- បានតុបតែងលម្អបំភ្លឺភ្លើងពណ៌នៅខាងមុខស្ថាប័នព្រឹទ្ធសភា និងដាក់តាំងព្រះឆាយាល័ក្ខណ៍**ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា និងធ្វើហ្វុងអក្សរ ចងបដា ពាក្យស្លោក ក្នុងឱកាសនៃពិធីបុណ្យផ្សេងៗ។

### ៤.៦-ការងារអគ្គាធិការដ្ឋាន៖

- បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆ្នាំ២០២៤ ចំនួន១៩៨លើក។
- បានជួបប្រជុំជាមួយនាយកដ្ឋានរដ្ឋបាល នាយកដ្ឋានផែនការ និងសរុប នាយកដ្ឋានគ្រប់គ្រងបុគ្គលិក នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស នាយកដ្ឋានគ្រប់គ្រងអគារ សារពើភ័ណ្ឌ និងសំណង់ បណ្ណសារដ្ឋាន និងអង្គភាពសន្តិសុខ ព្រមទាំងបានរៀបចំរបាយការណ៍ស្តីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានរៀបចំរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវាប្រចាំខែនីមួយៗ និងប្រចាំឆ្នាំ២០២៤។
- បានចុះត្រួតពិនិត្យវត្តមានជាក់ស្តែងតាមនាយកដ្ឋាននានា ប្រចាំឆ្នាំ២០២៤ ចំនួន១៨លើក ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមាន ដែលនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។

- បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមានប្រចាំថ្ងៃ ចំនួន៣៦២លើក ប្រចាំសប្តាហ៍ ចំនួន ៣៦លើក និងប្រចាំខែនីមួយៗ ឆ្នាំ២០២៤ ដែលគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារតាមអគារ និង សណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា និង
- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីរាជការតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## II-ទិសដៅការងារឆ្នាំ២០២៥

### ១- មុខងារនីតិកម្ម

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ប្រជុំពេញអង្គព្រឹទ្ធសភា និងប្រជុំព្រឹទ្ធសភា ជាវិសាមញ្ញ នីតិកាលទី៥។

### ២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជួបសវនាការជាមួយក្រសួង ស្ថាប័ន និងការចុះបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តា ខេត្តនានា និង
- ត្រៀមផ្តល់សេវាជូនសមាជិក សមាជិកាព្រឹទ្ធសភា ចុះបំពេញការងារតាមវិស័យរបស់គណៈកម្មការ និងចុះប្រាស្រ័យទាក់ទងជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ នៅមូលដ្ឋាន នាវិស្សមកាលរបស់ព្រឹទ្ធសភា រយៈពេល៣ខែ (ចាប់ពីថ្ងៃទី៦ ខែមករា ដល់ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៥) ឱ្យបានល្អប្រសើរ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

### ៣- មុខងារតំណាង

- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋនៅមូលដ្ឋាន ពិភាក្សាការងារជាមួយអាជ្ញាធរដែនដី ចុះពិនិត្យ វឌ្ឍនភាពនៃការអភិវឌ្ឍ នៅថ្នាក់ក្រោមជាតិ ចូលរួមពិធីសាសនា និងពិធីផ្លូវការផ្សេងៗនៅ រាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។
- បន្តទទួលពាក្យបណ្តឹង និងសហការជាមួយក្រសួង ស្ថាប័ន មានសមត្ថកិច្ច ដើម្បីដោះស្រាយបណ្តឹង ជូនប្រជាពលរដ្ឋ។
- ត្រៀមទទួលដំណើរទស្សនកិច្ចរបស់សាធារណជន និងសិស្ស និស្សិតមកកាន់ព្រឹទ្ធសភា និង
- ត្រៀមរៀបចំសារលិខិតជូនពរ លិខិតអបអរសាទរ លិខិតថ្លែងអំណរគុណ លិខិតរំលែកទុក្ខ របស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនឥស្សរជនជាន់ខ្ពស់ជាតិ-អន្តរជាតិ និងថ្នាក់ដឹកនាំតាមក្រសួង-ស្ថាប័ននានា។

### ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងពិធីជំនួបជាមួយឥស្សរជនជាន់ខ្ពស់ បរទេស និងអង្គទូតនានានៃបណ្តាប្រទេសជាមិត្ត។

- ត្រៀមលក្ខណៈរៀបចំដំណើរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញទស្សនកិច្ចផ្លូវការ ចូលរួមកិច្ចប្រជុំ វេទិកា សិក្ខាសាលា និងកម្មវិធីផ្សេងៗ នៅក្រៅប្រទេស។
- ត្រៀមផ្តល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកានានា កម្មវិធីជំនួប កម្មវិធីផ្លូវការ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ។
- ត្រៀមស្រាវជ្រាវ បកប្រែ និងផលិតឯកសារជំនួយស្មារតី សុន្ទរកថាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបជាមួយភ្ញៀវអន្តរជាតិក្នុងជំនួបសវនាការ កិច្ចប្រជុំ និងទស្សនកិច្ចនានា និង
- បន្តសហការជាមួយដៃគូសំខាន់ៗ អនុវត្តកម្មវិធីសហប្រតិបត្តិការ និងបន្តស្វែងរកជំនួយសម្រាប់អភិវឌ្ឍន៍ស្ថាប័ន ធនធានមនុស្ស និងបច្ចេកវិទ្យាព័ត៌មាន។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

- ត្រៀមផ្តល់សេវាសំខាន់ៗជាច្រើន ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួន មានជាអាទិ៍៖ កិច្ចការរដ្ឋបាល ហិរញ្ញវត្ថុ ការងារផ្គត់ផ្គង់ សេវាដឹកជញ្ជូន សេវាច្បាប់ សេវាស្រាវជ្រាវ ពិធីការ និងបដិសណ្ឋារកិច្ច ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ ការងារសាងសង់ ជួសជុល កែលម្អ ថែទាំបរិស្ថាន អនាម័យ និងសន្តិសុខ សណ្តាប់ធ្នាប់ក្នុងបរិវេណព្រឹទ្ធសភា ឱ្យបានល្អ ស្រស់បំព្រង ក្នុងបរិបទសភាបៃតង ដើម្បីឆ្លើយតបទៅនឹងកំណើន និងសំណូមពរ ការងារលើមុខងារស្នូលទាំង៣ និងការងារការទូតសភា ដែលជាមុខងារអាទិភាពសំខាន់មួយក្នុងចំណោមមុខងារអាទិភាពសំខាន់របស់ព្រឹទ្ធសភា នីតិកាលទី៥។
- ត្រៀមរៀបចំរបាយការណ៍ទូទាត់ថវិកាព្រឹទ្ធសភាប្រចាំឆមាសទី១ និងប្រចាំឆ្នាំ២០២៥ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា។
- ត្រៀមកសាង និងការពារគម្រោងថវិកាឆ្នាំ២០២៦ ក្នុងកម្រិតរដ្ឋបាល និងនយោបាយជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ត្រៀមអនុវត្តផែនការបណ្តុះបណ្តាលសម្រាប់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឆ្នាំ ២០២៥។
- ត្រៀមជួបប្រជុំជាមួយ **ឯកឧត្តម លោកជំទាវ ជាអគ្គនាយក អគ្គនាយិកា** ពាក់ព័ន្ធនឹងការអនុវត្តផែនការយុទ្ធសាស្ត្រ ឆ្នាំ២០២១-២០៣០ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- ត្រៀមរៀបចំមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលនានា។
- ត្រៀមរៀបចំផលិតខ្សែវីដេអូព័ត៌មានរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- ត្រៀមបោះពុម្ពសៀវភៅកំណត់ហេតុសង្ខេប និងកំណត់ហេតុពិស្តារ នៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំពេញអង្គ រួមទាំងឯកសារលិខិតបទដ្ឋានគតិយុត្តផ្សេងៗ។
- តាមដាន និងជំរុញការងារសាងសង់អគារថ្មីព្រឹទ្ធសភា ដើម្បីឱ្យរួចរាល់តាមការគ្រោងទុកនៅដំណាច់ឆ្នាំ២០២៥។
- បន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានារួមមាន ការសាងសង់អគារ ការជួសជុល ថែទាំ កែលម្អបរិស្ថាន អនាម័យ សួនច្បារ ប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹក ប្រព័ន្ធលូ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធសន្តិសុខ

ផ្ទៃក្នុងព្រឹទ្ធសភា ប្រកបដោយសុខសុវត្ថិភាព។

- បន្តផ្តល់សេវាផ្គត់ផ្គង់សម្ភារ ថវិកា មធ្យោបាយដឹកជញ្ជូន និងសេវាសំខាន់ៗផ្សេងទៀតជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនឱ្យបានទាន់ពេលវេលា និងល្អប្រសើរ និង
- បន្តការចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## III-សេចក្តីសន្និដ្ឋាន

ក្នុងឆ្នាំ២០២៤នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអនុវត្តការងារសម្រេចបានលទ្ធផលល្អប្រសើរជាងឆ្នាំ២០២៣ លើមុខងារស្នូលទាំង៣របស់ព្រឹទ្ធសភា ជាពិសេសការងារការទូតសភា ដែលជាមុខងារអាទិភាពចំបងសម្រាប់ព្រឹទ្ធសភានីតិកាលទី៥ នេះ។ លទ្ធផលទាំងនេះជាសូចនាករនៃការដឹកនាំគ្រប់គ្រង និងការខិតខំប្រឹងប្រែងដោយស្មារតីទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

ដើម្បីឱ្យលទ្ធផលការងារឆ្នាំ២០២៥ សម្រេចបានលទ្ធផលច្រើនជាងឆ្នាំ២០២៤ គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពទាំងអស់ត្រូវបន្តយកចិត្តទុកដាក់បំពេញការងារប្រកបដោយឆន្ទៈ មនសិការ បុរេសកម្ម សកម្ម អន្តរសកម្ម ប្រសិទ្ធភាព និងប្រសិទ្ធផល ឆ្លើយតបបានទៅនឹងតម្រូវការការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងសម្រេចបានបេសកកម្មរបស់ស្ថាប័ន។

ឯកភាព សាមគ្គីភាព និងសហប្រតិបត្តិការគ្នាដ៏ល្អប្រពៃ គឺជាមូលដ្ឋានគ្រឹះនៃដំណើរឈានទៅមុខប្រកបដោយជោគជ័យរបស់ស្ថាប័នព្រឹទ្ធសភាយើង។

ថ្ងៃសុក្រ ១៥កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៥

**អគ្គលេខាធិការ**

**ឡាយ សំកុល**